កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែ មករា | ឆ្នាំ ២០២១ | លេខទី ១៣៥

www.catholiccambodia.org/km/ | www.facebook.com/RVAKHMER/ | https://khmer.rvasia.org/

January, 2021 | #135

## កិច្ចការទាំង៣ ក្នុងរដូវអប់រំពិសេស
# អធិដ្ឋាន តមអាហារ ចែកទាន



## ចូរកែប្រែចិត្តគំនិតហើយជឿលើដំណឹងល្អចុះ

### កុមារកម្ពុជានឹងរួចផុតពីអំពើហិង្សានៅក្នុងសាលារៀន
ទំព័រ-៣



### អាស៊ាន ជាតំបន់នៃប្រព័ន្ធតម្លៃសង្គមចម្រុះខុសពីតំបន់នានា ប៉ុន្តែគួរយកចិត្តទុកដាក់លើបញ្ហាក្រមសីលធម៌
ទំព័រ-៧

### ប្រជាពលរដ្ឋព្រួយបារម្ភអំពីការកើនឡើងតម្លៃម្ហូបអាហារនៅក្នុងពេលកូវីដ-១៩
ទំព័រ-៩



### CCHS បានផ្តល់សេវាសុខភាពដល់អ្នកជំងឺចំនួន១៩៩៨នាក់ និងបានពិគ្រោះជំងឺជាង៤៤០០ដង ក្នុងឆ្នាំ២០២០
ទំព័រ-១៧



# «ចូរកែប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ»



បងប្អូនជាទីស្រលាញ់ពាក្យមួយឃ្លាខាងលើនេះ យើងតែងតែឮជានិច្ចក្នុងថ្ងៃបុណ្យរោយផេះ ដែលចាប់ផ្ដើមចូលក្នុងរដូវអប់រំពិសេស (រដូវ៤០ថ្ងៃ ឬរដូវត្រណម)។

តើអ្វីដែលបងប្អូនត្រូវកែប្រែសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់បងប្អូន? មានតែបងប្អូនជាអ្នកសម្រេចចិត្ត ។

ក្នុងពេលនេះប្រទេសកម្ពុជាកំពុងព្រួយបារម្ភ អំពីការឆ្លងរីករាលដាលមេរោគកូវីដ-១៩ នៅក្នុងសហគមន៍ ជាមួយព្រឹត្តិការណ៍សហគមន៍ ថ្ងៃទី២០ កុម្ភៈ។ មានតំបន់ជាច្រើនបានបិទ និងផ្អាកដំណើរបណ្ដោះអាសន្ន។ ក្នុងពេលកូវីដផ្ទុះឡើងម្ដងៗ ក៏ជាពេលដែលរំលឹកបងប្អូនផងដែរ ឱ្យកែប្រែរបៀបរស់នៅ។

ក្នុងនោះក្រសួងសុខាភិបាល ក៏បានណែនាំរួចហើយដែរអំពី ការរក្សាអនាម័យរក្សាគម្លាតសង្គម ពាក់ម៉ាស វាស់កំដៅជាប្រចាំជាដើម។ ម្ដងហើយម្ដងទៀត សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានរំឭកអំពីវិធានការការពារ កូវីដ-១៩ ៣ការពារ និង៣កុំ។ «៣ការពារ» គឺ ពាក់ម៉ាស់ លាងដៃ គម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល (ចាប់ពី១ម៉ែត្រកន្លះឡើងទៅឱ្យបានគ្រប់គ្នា នៅគ្រប់ទីកន្លែង និងអនុវត្តន៍ឱ្យបានគ្រប់គ្នា) ចំណុច ៣ ការពារ នេះ សំខាន់ខ្លាំងណាស់ ដូច្នេះទើបអាចយកឈ្នះលើជំងឺ កូវីដ-១៩ បានដោយជោគជ័យ។ «៣កុំ» គឺកុំចូលទៅកន្លែងបិទជិត គ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក រកកន្លែងមានខ្យល់ចេញចូល។ កុំទៅកន្លែងមនុស្សច្រើនកុះករ។ កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នាជាដើម។ ក្នុងបរិបទនេះបងប្អូនគួរតែអនុវត្តន៍បែបនេះ គឺរៀនកែប្រែរបៀបរស់នៅ តាមគន្លងថ្មីនេះជាដាច់ខាត។

ចុះជំនឿរបស់យើងជាគ្រីស្តបរិស័ទយ៉ាងដូចម្ដេចវិញ? គឺបងប្អូនបានស្ដាប់ច្រើនរួចមកហើយ អំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ជាព្រះបិតា។ ដោយសារជំនឿបងប្អូនបានទទួលអគ្គសញ្ញាជ្រមុជទឹក។ ដោយសារជំនឿ យើងជឿថាព្រះអង្គបានត្រាស់ហៅចំឈ្មោះរបស់យើងម្នាក់ៗ ឱ្យទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលពោរពេញដោយធម៌មេត្តាករុណា និងសេចក្ដីស្រលាញ់ដ៏លើសលប់។ តាមរយៈអគ្គសញ្ញាជ្រមុជទឹក យើងទទួលបានខ្យល់ដង្ហើមថ្មី គឺកើតជាថ្មីដោយទឹក និងព្រះវិញ្ញាណដ៏វិសុទ្ធ ទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។

បើព្រះជាម្ចាស់ ជាព្រះបិតារបស់យើង ហើយព្រះអង្គជាសេចក្ដីស្រលាញ់ តើមានមូលហេតុណាខ្លះដែលរាំងជីវិតបងប្អូនមិនឱ្យកែប្រែ ឬវិលមករកសេចក្ដីស្រលាញ់របស់ព្រះអង្គបាន?

លោកអភិបាលព្រះសហគមន៍កាតូលិកកម្ពុជា ភូមិភាគភ្នំពេញ អូលីវីយេ នៅថ្ងៃរោយផេះបានអញ្ជើញគ្រីស្តបរិស័ទទាំងអស់នៅក្នុងរដូវអប់រំពិសេសនេះ យកចិត្តទុកដាក់៖ ថែរក្សាជំនឿ ថែរក្សាសេចក្ដីសង្ឃឹម សម្ដែងធម៌មេត្តាករុណា និងតមអាហារ។

ទាក់ទងនឹងការតមអាហារឬវៀរចាក អំពើនានាក្នុងជីវិតដែលនាំឱ្យឃ្លាតឆ្ងាយពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់។ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ មានប្រសាសន៍សួរទៅ គ្រីស្តបរិស័ទទាំងអស់គ្នាថា តើអ្នកចង់វៀរចាកអ្វីខ្លះក្នុងរដូវអប់រំពិសេសនេះ?

១. វៀរចាកពាក្យសម្ដីអាក្រក់ ហើយនិយាយពាក្យល្អៗ
២. វៀរចាកភាពសោកសៅ ហើយបំពេញដោយចិត្តកតញ្ញូ។
៣. វៀរចាកការខឹងក្រោធ ហើយបំពេញដោយចិត្តអត់ធ្មត់។
៤. វៀរចាកទុទិដ្ឋិនិយម ហើយបំពេញដោយសេចក្ដីសង្ឃឹម។
៥. វៀរចាកការព្រួយបារម្ភ ហើយជឿទុកចិត្តលើព្រះជាម្ចាស់។
៦. វៀរចាកការរអ៊ូរទាំ ហើយពិចារណាដោយសុភាព។
៧. វៀរចាកភាពតានតឹង ហើយអធិដ្ឋានច្រើន។
៨. វៀរចាកភាពល្វីងជូរចត់ ហើយតាំងចិត្តរីករាយ។
៩. វៀរចាកភាពអាត្មានិយម ហើយមានចិត្តមេត្តាករុណា។
១០. វៀរចាកការស្អប់គ្នា ហើយផ្សះផ្សាគ្នា។
១១. វៀរចាកការនិយាយច្រើន ហើយទៅជាអ្នកស្ងៀមស្ងាត់ និងស្ដាប់៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កុមារកម្ពុជានឹងរួចផុតពីអំពើហិង្សានៅក្នុងសាលារៀន

*អត្ថបទ៖ អរិយបុត្រ*

កុមារកម្ពុជាកំពុងតែត្រូវបានអង្គការមួយចំនួនសហការគ្នាដើម្បីធានាថា ពួកគេនឹងរួចផុតពីអំពើហិង្សានៅក្នុងសាលារៀន។



*រូបភាពតំណាង។ រូបភាព៖ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភ្នំពេញ*

កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១ អង្គការបីដែលរួមមាន អង្គការសង្គ្រោះកុមារ ( Save the Children) រួមទាំងដៃគូរួមមាន អង្គការទស្សនៈពិភពលោក ( World Vision) និងអង្គការ ប្លែនអន្តរជាតិ(Plan International) បានសម្ពោធជាផ្លូវការនូវគម្រោងមួយដែលមានឈ្មោះថា «បញ្ចប់អំពើហិង្សាលើកុមារនៅក្នុងសាលារៀននៅកម្ពុជា» ដោយគម្រោងនេះទទួលបានជំនួយតាមរយៈមូលនិធិបញ្ចប់អំពើហិង្សា និងម្ចាស់ជំនួយដែលពាក់ព័ន្ធមួយចំនួនទៀត។

ពិធីប្រកាសគម្រោងនេះក៏មានការដឹងឮពីអ្នកតំណាងមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាផងដែរ ហើយក៏មានការចូលរួមពីតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើការបញ្ចប់អំពើហិង្សាលើកុមារ អាជ្ញាធរមូលដ្ឋាន កុមារ និងយុវជនផងដែរ។

គម្រោងនឹងជួយគាំទ្រដល់កុមារប្រមាណ ១៣,០០០នាក់ រួមទាំងកុមារដែលមិនកំណត់អត្តសញ្ញាណភេទខ្លួនឯង និងកុមារមានពិការភាពនៅក្នុងខេត្តសៀមរាប និងព្រះវិហារ។ គម្រោងនេះមានគោលបំណងកាត់បន្ថយអំពើហិង្សាលើកុមារនៅក្នុងនិងជុំវិញសាលារៀនដោយប្រើប្រាស់ឧបករណ៍បច្ចេកទេស និងវិធីសា ស្រ្តនានាផ្អែកទៅលើភស្តុតាងដែលបានមកពីការសិក្សាស្រាវជ្រាវ។

អង្គការSave the Children នឹងដឹកនាំការអនុវត្តគម្រោងទាំងមូល ធានាពីគុណភាពលទ្ធផល និងការសហការជាមួយថ្នាក់ជាតិ។ ជាមួយគ្នានេះដែរ អង្គការទស្សនពិភពលោកនឹងអនុវត្តន៍គម្រោងនេះនៅក្នុងខេត្តព្រះវិហារ ហើយអង្គការភ្លែនអន្តរជាតិកម្ពុជា នឹងអនុវត្តន៍នៅក្នុងខេត្តសៀមរាប។

កុមារដែលរងអំពើហិង្សា មានផលអវិជ្ជមានរយៈពេលយូរលើការអភិវឌ្ឍរបស់ពួកគេ។ យោងតាមការស្ទង់មតិអំពីអំពើហិង្សាលើកុមារនៅកម្ពុជាកាលពីឆ្នាំ២០១៣ ជាងពាក់កណ្តាលនៃស្រ្តី(៥២.៧%) និងបុរស (៥៤,២%) ដែលមានអាយុពី១៨-២៤ឆ្នាំ បានឱ្យដឹងថា យ៉ាងហោចណាស់ពួកគេទទួលរងអំពើហិង្សាលើរាងកាយម្តង មុនដែលពួកគេអាយុ១៨ឆ្នាំ។

ការសិក្សាបានគូសបញ្ជាក់បន្ថែមទៀតថា អំពើហិង្សានៅតាមសាលារៀនច្រើនតែកើតឡើងរវាងកុមារដែលមានអាយុដំណាលគ្នា ប៉ុន្តែគ្រូបង្រៀនជាញឹកញាប់គឺជាអ្នកប្រព្រឹត្តអំពើហិង្សាទៅលើកុមារនៅខាងក្រៅផ្ទះ។

លោកស្រី អេលីហ្សាបេត តៀស នាយិកាអង្គការSave the Children ប្រចាំប្រទេសកម្ពុជា បានលើកឡើងថា អំពើហិង្សាលើកុមារជាពិសេសអំពើហិង្សាផ្អែកយេនឌ័រ និងការសម្លុតបានរួមចំណែកកត្តាធំក្នុងការបោះ បង់ចោលការសិក្សាក្នុងចំណោមកុមារមានពិការភាព។

លោកស្រីតៀស ក៏បានកត់សម្គាល់ផងដែរថា កុមារប្រឈមនឹងភាពងាយរងគ្រោះផ្សេងៗគ្នាផ្អែកលើយេនឌ័ររបស់ពួកគេ។ ក្មេងស្រីភាគច្រើនទទួលរងការរំលោភបំពានផ្លូវចិត្ត ការរំលោភបំពានតាមអ៊ីនធឺណិត អំពើហិង្សាផ្លូវភេទ និងការរំលោភបំពាន ខណៈពេលដែលក្មេងប្រុសទទួលរងនូវអំពើហិង្សា និងការដាក់ទណ្ឌកម្មលើរាងកាយ។ ការអនុវត្តការការពារកុមារត្រូវការឆ្លើយតបឱ្យបានត្រឹមត្រូវ ផ្អែកលើលំនាំទាំងនេះ។

លោកស្រីតៀស បានមានប្រសាសន៍ថា៖«តាមរយៈគម្រោងនេះ អង្គការSave the Children និងដៃគូនឹងពង្រឹងក្របខណ្ឌគោលនយោបាយការការពារកុមារនៅកម្ពុជា តាមរយៈការអភិវឌ្ឍការអនុម័តនិងការ ផ្សព្វផ្សាយសៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារនៅក្នុងសាលារៀន»។

លោកស្រីបានបន្តទៀតថា៖ «យើងក៏នឹងគាំទ្រក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាកល្បងអនុវត្តន៍សៀវភៅណែនាំប្រតិបត្តិស្តីពីកិច្ចការពារកុមារ នៅក្នុងសាលារៀន នៅក្នុងសាលាបឋមសិក្សាគោលដៅ ដោយបង្កើតនូវយន្តការកិច្ចការពារកុមារនៅតាមសាលា និងផ្សារភ្ជាប់ជាមួយយន្តការកិច្ចការពារកុមារដែលមានស្រាប់ក្នុងសហគមន៍»។

លោកស្រី គ្វីននេត វង នាយិកាអង្គការប្លែនអន្តរជាតិ (Plan International ) ប្រចាំនៅកម្ពុជា បានឱ្យដឹងដែរថា គម្រោងនេះក៏នឹងគាំទ្រសាលាគោលដៅក្នុងការបង្កើតប្រព័ន្ធត្រួតពិនិត្យស្ថិតិពីអំពើហិង្សាលើកុមារ ព្រមទាំងដាក់ឱ្យអនុវត្តក្រមសីលធម៌កិច្ចការពារកុមារ។

លោកស្រីគ្វីននេត បានថ្លែងថា ៖ «ប្រព័ន្ធទាំងនេះនឹងជួយសាលាក្នុងការតាមដានអំពើហិង្សាលើកុមារ និងជួយឱ្យមានការឆ្លើយតបទាន់ពេលវេលាដើម្បីការពារកុមារពីការបោះបង់ចោលការសិក្សា»។

គម្រោង «បញ្ចប់អំពើហិង្សាលើកុមារនៅសាលារៀន» នឹងផ្តល់សិទ្ធិអំណាចដល់សាលា និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីអំពើហិង្សានៅក្នុងសាលា៕

# អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាថ្មីត្រូវបានតែងតាំងជំនួសលោកស្រី រ៉ូណា ស្មីត

*អត្ថបទ៖ អមរិន្ទ្រ ដានុត*

លោកសាស្ត្រាចារ្យ វិទីត ម៉ុនតារបន (Vitit MUNTARBHORN) ជាជនជាតិថៃ ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិតែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ជំនួសអ្នកស្រី រ៉ូណា ស្មីត ដែលបានបញ្ចប់អណត្តិ។

លោកសាស្ត្រាចារ្យ ត្រូវបានគេស្គាល់ក្នុងវិស័យការងារសិទ្ធិមនុស្សនិងនីតិរដ្ឋ ដែលលោកបានប្រឡូកក្នុងការអប់រំ និងតស៊ូមតិជាច្រើនផងដែរ។

នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) លោកស្រី ចក់ សុភាព បានឱ្យដឹងថា លោកវិទីត ម៉ុនតារបន ត្រូវបានតែងតាំងជាអ្នកជំនាញការឯករាជ្យរបស់អង្គការសហប្រជាជាតិដំបូងគេបង្អស់ ទទួលបន្ទុកលើកិច្ចការហឹង្សា និងការរើសអើងដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

លោកស្រីបន្តថា លោកវិទីត ម៉ុនតារបន ក៏ជាសហប្រធានក្នុងការតាក់តែងគោលការណ៍យ៉កយ៉ាកាតា ដែលចែងពីគោលការណ៍និងវិធានលើកកម្ពស់និងការពារសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ហើយលោកបានទទួលជ័យលាភីផ្នែកការអប់រំពីអង្គការយូណេស្កូ ក្នុងឆ្នាំ២០១៤ ផងដែរ។

លោកស្រីចក់ សុភាព បានមានប្រសាសន៍ថា៖ «ខ្ញុំសង្ឃឹមថា តាមរយៈបទពិសោធន៍ ការចូលរួមយ៉ាងសកម្មរបស់លោកសាស្ត្រាចារ្យកន្លងមក និងការយល់ពីបរិបទសិទ្ធិមនុស្សក្នុងតំបន់ លោកសាស្ត្រាចារ្យនឹងអាចបំពេញអណត្តិរបស់លោកក្នុងការរាយការណ៍ពីស្ថានភាពសិទ្ធិមនុស្ស»។

លោកស្រីបន្តថា៖«លោកនឹងធ្វើការជាមួយភាគីពាក់ព័ន្ធ ជាពិសេសធានានូវធាតុចូលពីសហគមន៍ដែលសំឡេងមិនសូវបានយកចិត្តទុកដាក់ ដើម្បីស្តារនិងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា»។

នាយិការូបនេះបានបញ្ជាក់បន្ថែមថា អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ធ្លាប់ចូលរួមក្នុងសន្និសីទនិងបេសកកម្មមួយចំនួនកន្លងមក ដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក៏បានរៀបចំឬទទួលទស្សនកិច្ចរបស់លោក និងក្រុមការងារ ពាក់ព័ន្ធនឹងកិច្ចការសិទ្ធិមនុស្ស និងនីតិរដ្ឋផងដែរ។

លោក វិទីត ម៉ុនតារបន គឺជាអ្នកជំនាញសិទ្ធិមនុស្សអន្តរជាតិ និងជាសាស្ត្រាចារ្យច្បាប់នៅសកលវិទ្យាល័យ Chulalongkorn នៅទីក្រុងបាងកកប្រទេសថៃ ហើយលោកក៏នឹងត្រូវចូលមកកាន់តំណែងថ្មីជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជានៅក្នុងខែឧសភាខាងមុខ។

គួរបញ្ជាក់ផងដែរថា លោកស្រី រ៉ូណា ស្មីត (Rhona Smith) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សកម្ពុជា នឹងត្រូវបញ្ចប់អាណត្តិ៥ឆ្នាំរបស់លោកស្រីនៅដើមឆ្នាំ២០២១នេះ បន្ទាប់ពីលោកស្រីត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា កាលពីខែឧសភា ឆ្នាំ២០១៥៕

# ប្រជាជនកម្ពុជាមានចំនួនជាង១៥លាននាក់ ក្នុងនោះស្រីមានច្រើនជាងបុរស

របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដែលជាជំរឿនលើកទីបី ក្រោយប្រទេសឆ្លងកាត់ក្នុងសង្គ្រាមកន្លងមកត្រូវបានប្រកាសផ្សព្វផ្សាយជាផ្លូវការកាលពីព្រឹកថ្ងៃអង្គារ ទី២៦ ខែមករា ឆ្នាំ២០២១ ក្រោមអធិបតីភាពរបស់សម្តេចក្រឡាហោម ស ខេងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ។

យោងតាមលទ្ធផលជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ បានឱ្យដឹងថា ចំនួនប្រជាជនសរុបមានចំនួន១៥.៥៥២.២២១ នាក់ ក្នុងនោះប្រុសចំនួន ៧.៥៧១.៨៣៧ នាក់ (៤៨.៧%) និងស្រីចំនួន៧.៩៨០.៣៧៤ នាក់ (៥១.៣%)។ អត្រាកំណើនប្រជាជនមធ្យមប្រចាំឆ្នាំគឺ ១.៤% ។

ដូចគ្នានេះដែរ លទ្ធផលជំរឿនឆ្នាំ២០០៨ ចំនួនប្រជាជនសរុបមានចំនួន ១៣.៤ លាននាក់ ពោលគឺចាប់ពីឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១៩ ចំនួនប្រជាជនក្នុងប្រទេសកម្ពុជាបានកើនឡើងចំនួន ២,២ លាននាក់។

ភាគរយនៃប្រជាជនរស់នៅទីតំបន់ទីប្រជុំជនមានចំនួន ៣៩,៤ ភាគរយ និងនៅជនបទមាន ៦០,៦ ភាគរយ។ គ្រួសារសរុបនៅទូទាំង ប្រទេសមានចំនួន ៣.៥៥៣.០២១ គ្រួសារ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងផែនការបានលើកឡើងថា ខេត្តចំនួន៤ដែលមានប្រជាជនច្រើនជាង ១ លាននាក់ គឺ រាជធានីភ្នំពេញ (២,៣ លាននាក់), ខេត្តកណ្តាល (១,២ លាននាក់), ខេត្តព្រៃវែង (១,១ លាននាក់) និងខេត្តសៀមរាប (១,០ លាននាក់)។

លោក ស ខេង បានលើកឡើងថា ការដឹកនាំគ្រប់សកម្មភាពការងារជំរឿនទូទៅប្រជាជនឆ្នាំ២០១៩ បានប្រព្រឹត្តទៅល្អប្រសើរនិងរលូនតាមផែនការជំរឿន។ ជំរឿនប្រជាជន គឺជាប្រភពព័ត៌មានតែមួយគត់ស្តីអំពីចំនួននិងចរិតលក្ខណៈប្រជាជន។

លោកបានថ្លែងថា៖«ជំរឿនប្រជាជនមាន វិសាលភាពរឹងមាំ ល្អិតល្អន់ និងអាចផ្តល់ឱ្យនូវចំនួនប្រជាជនក្នុងតំបន់រហូតដល់ថ្នាក់តូចៗថែមទៀត ដែលប្រភព ទិន្នន័យផ្សេងៗទៀតមិនមានឡើយ។ ជំរឿនក៏ផ្តល់ជូនផងដែរនូវក្របខ័ណ្ឌជ្រើសរើសគំរូ ក៏ដូចជាមូលដ្ឋាន ឬព្យាករណ៍ប្រជាជន ដែលជាកត្តាសំខាន់សម្រាប់ ការងារផែនការរយៈពេលវែង»៕



*រូបភាព៖ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភ្នំពេញ*

# គ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០២០មានការថយចុះជាង២០% បើធៀបនឹងឆ្នាំ ២០១៩

*អត្ថបទ៖ អមរិន្ទ ដានុត*

របាយការណ៍របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកដែលបានបង្ហាញក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ឱ្យដឹងថា ករណីគ្រោះថ្នាក់ចរាចរណ៍ឆ្នាំ២០២០ កន្លងទៅមានការថយចុះចំនួន ៩៤២លើក ស្មើនឹង២៣% ធៀបនឹងឆ្នាំ២០១៩ ។

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកបានលើកឡើងចំនួនអ្នកស្លាប់បានថយចុះចំនួន ៣៣៥នាក់ ស្មើនឹង១៧% និងចំនួនអ្នករបួសបានថយចុះចំនួន ១.៤៥៥នាក់ស្មើនឹង ២៤% គ្រោះថ្នាក់ភាគច្រើនកើតឡើងដោយសារការបើកបរលើសល្បឿនកំណត់ដោយច្បាប់ និងមិនគោរពច្បាប់ចរាចរណ៍។

លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន បានសម្តែងនូវការសាទរប្រកបដោយមោទនភាព និងបានឯកភាពតាមរបាយការណ៍របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ ព្រោះថាលទ្ធផលនេះកើតចេញពីការខិតខំប្រឹងប្រែង ប្រកបដោយការច្នៃប្រឌិត និងមានយុទ្ធសាស្ត្រច្បាស់លាស់ និងក្រោមកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយពីភាគីពាក់ព័ន្ធ។



*លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន។ រូបភាព៖ សហការី*

> ក្រសួងបានទិញកាមេរ៉ាចាប់ល្បឿន និងបានសហការជាមួយស្ថាប័នពាក់ព័ន្ធ ល្បាតពេលយប់សំដៅទប់ស្កាត់ការបើកបរលើសល្បឿនកំណត់ និងដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដោយច្បាប់

លោកបានគូសបញ្ជាក់ថា៖«ដើម្បីទប់ស្កាត់ការបើកបរលើសល្បឿនកំណត់ដោយច្បាប់ ក្រសួងបានទិញកាមេរ៉ាចាប់ល្បឿន និងបានសហការជាមួយស្ថាប័នពាក់ព័ន្ធ ល្បាតពេលយប់សំដៅទប់ស្កាត់ការបើកបរលើសល្បឿនកំណត់ និងដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដោយច្បាប់»។

ក្រសួងក៏ដូចជាអនុគណៈកម្មការទី១ បានសហការជាមួយអនុគណៈកម្មការផ្សេងៗទៀត ព្រមទាំងក្រសួង-ស្ថាប័ន អង្គភាពអាជ្ញាធរពាក់ព័ន្ធ អង្គការ និងដៃគូអភិវឌ្ឍន៍ បានខិតខំប្រឹងប្រែងអភិវឌ្ឍ និងធ្វើទំនើបកម្មទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ សំដៅ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។

ជាមួយគ្នានេះដែរ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានថ្លែងការកោតសរសើរដល់ថ្នាក់ដឹកនាំ និងមន្ត្រីបំពេញការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំប្រឹងប្រែងរក្សាសុវត្ថិភាព និងពង្រឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

លោកស ខេង បានណែនាំឱ្យអនុគណៈកម្មការទាំងអស់ធ្វើទំនើបកម្មទាំងផ្នែករឹង និងផ្នែកទន់ ជាពិសេស ក្រសួងសាធារណៈការ និងដឹកជញ្ជូន ដែលជាអនុគណៈកម្មការទី១ ត្រូវជំរុញការដឹកជញ្ជូនតាមផ្លូវដែក លុបបំបាត់ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ កែលម្អផ្លូវជើងកប ជួសជុលផ្លូវជង្ហុកសំបុកមាន់ ផ្លូវបែកស្រកានាគ ពង្រីកផ្លូវនៅតាមទីប្រជុំជន បំពាក់ភ្លើងសញ្ញា ផ្លាកសញ្ញា និងគំនូសសញ្ញាឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស។

លោកបានមានប្រសាសន៍ថា ៖ «ពង្រឹងការចុះបញ្ជីយានយន្ត ការចេញបណ្ណបើកបរ និងគុណភាពសាលាបើកបរយានយន្តគ្រប់ប្រភេទ លុបបំបាត់ការទិញដូរបណ្ណបើកបរទោះក្នុងរូបភាពណាក៏ដោយ និងអនុវត្តន៍ច្បាប់ចរាចរណ៍ឱ្យបានម៉ឺងម៉ាត់បំផុត»។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋជាអ្នកប្រើប្រាស់ផ្លូវទាំងអស់ចូលរួមអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោកឱ្យមានប្រសិទ្ធភាពបំផុត ដើម្បីចៀសវាងគ្រោះថ្នាក់ចរាចរណ៍នានាជាយថាហេតុ បណ្តាលឱ្យបាត់បង់មនុស្សជាទីស្រឡាញ់ ពិការភាព ខាតបង់ទ្រព្យសម្បត្តិ ក៏ដូចជាចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការសម្រេចឱ្យបាននូវគោលនយោបាយកាត់បន្ថយភាពក្រីក្រឱ្យកាន់តែមានប្រសិទ្ធភាព៕

# គេហទំព័របណ្ណសារសារមន្ទីរទួលស្លែងបានបើកដំណើរការជាផ្លូវការ

*អត្ថបទ៖ អរិយបុត្រ*

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រួមជាមួយនឹងដៃគូអភិវឌ្ឍន៍ដែលរួមមាន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (កយកា) និងអង្គការយូណេស្កូ បានប្រកាសដាក់ឲ្យដំណើរការជាផ្លូវការនូវគេហទំព័រសម្រាប់គម្រោងស្តីពី ការអភិរក្សនិងបញ្ចូលបណ្ណសារសារមន្ទីរទួលស្លែងទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លោកស្រី ភឿង សកុណា បានមានប្រសាសន៍ថា ៖ «បណ្ណសារត្រូវបានបញ្ចូលទៅក្នុងគេហទំព័រជាភាសាខ្មែរ និងអង់គ្លេស សម្រាប់ជួយសម្រួលដល់ប្រជាជនកម្ពុជានៅជនបទ យុវជន និងអ្នកស្រាវជ្រាវអន្តរជាតិ ហើយវាបានរួមចំណែកដល់ការអប់រំយុវជនអំពីសន្តិភាពនិងការចងចាំ»។

លោកស្រីលើកឡើងថា គេហទំព័រនេះនឹងផ្តល់ជូនសាធារណជននិងអ្នកស្រាវជ្រាវអាចចូលមើលមូលដ្ឋានទិន្នន័យពីរ ដែលត្រូវបានបង្កើតឡើងដោយគម្រោងមួយផ្អែកផ្អែកលើអ្នកជាប់ឃុំ និងមួយផ្អែកទៀតផ្អែកលើទិន្នន័យ។ អ្នកប្រើប្រាស់អាចចូលរួមក្នុងការកែលំអមុខងាររបស់គេហទំព័រ តាមរយៈវេទិកាផ្តល់មតិត្រឡប់ដែលត្រូវបានបញ្ចូលក្នុងវិបផតថល។

លោក នោ ហ្យន់ជូន (Rho HyunJun) ប្រធានតំណាង អង្គការកយកា បានឱ្យដឹងថា គោលបំណងនៃគម្រោងនេះ គឺដើម្បីអភិរក្សនិងធ្វើឌីជីថលបណ្ណសារនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលត្រូវបានចារលើការចងចាំអន្តរជាតិនៃការចុះឈ្មោះពិភពលោកក្នុងឆ្នាំ២០០៩, ដើម្បីគាំទ្រដល់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង, ដើម្បីអភិវឌ្ឍន៍ទៅជាកន្លែងកសាងការអប់រំ និងសន្តិភាពដែលយុវជន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសាធារណជនទូទៅ អាចទទួលបានព័ត៌មានអំពីប្រវត្តិសាស្ត្ររបស់ពួកគេ និងបន្តកិច្ចពិភាក្សាអំពីសន្តិភាពនិងអហិង្សា និងដើម្បីកសាងសមត្ថភាព បុគ្គលិកនៅ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីគ្រប់គ្រងបណ្ណសារ។

សូមបញ្ជាក់ថា មុនពេលអនុវត្តគម្រោងនេះ មិនមានមនុស្សច្រើនទេបានដឹងអំពីឯកសាររាប់ពាន់ដែលបានទុកនៅក្នុងបរិវេណសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បន្ទាប់ពីការរំដោះថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ។

តាមរយៈគម្រោងនេះ រាល់ឯកសារទាំងអស់ត្រូវបានថែរក្សាយ៉ាងល្អ រហូតមកដល់សព្វថ្ងៃនេះ ហើយឥឡូវនេះអ្នករាល់គ្នាអាចចូលមើលបាន។ គម្រោងនេះដែរ បានលើកកម្ពស់សន្តិភាព និងកិច្ចពិភាក្សាអន្តរវប្បធម៌ សម្របសម្រួលកិច្ចខិតខំប្រឹងប្រែងផ្សះផ្សា និងពង្រីកការផ្សព្វផ្សាយ រួមទាំងតាមរយៈការអភិរក្សនិងការធ្វើឌីជីថល បណ្ណសារសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

តាមរយៈគម្រោងនេះសរុបចំនួន ៤០៥.៧៨២ ទំព័រ ត្រូវបានធ្វើឌីជីថល និង ៧៤៥.៤៩៤ទំព័រ ត្រូវបានរក្សាទុកតាមរយៈគម្រោង រួមមាន ការបោះពុម្ពរូបថត ហ្វីល ចម្លើយសារភាព ជីវប្រវត្តិ បញ្ជី សៀវភៅបដិវត្ត ទស្សនាវដ្តី សៀវភៅសរសេរដោយដៃរបស់ខ្មែរក្រហម និងឯកសារផ្សេងទៀត៕

# កម្ពុជាមានវត្តមាននៅសល់សត្វក្រពើភ្នំច្រើនជាងគេលើពិភពលោក




*ក្រពើភ្នំដែលអង្គការWWF ថតបាន។ រូបភាព៖ អង្គការ WWF Cambodia*

*អត្ថបទ៖ អមរិន្ទ ដានុត*

នាពេលបច្ចុប្បន្ននេះកម្ពុជានៅសេសសល់ក្រពើភ្នំដែលជាសត្វដ៏កម្របំផុតនៅលើពិភពលោកចំនួនប្រមាណ២០០-៣០០ក្បាល ហើយក្នុងចំណោមនេះស្ថិតនៅក្នុងតំបន់ជួរភ្នំក្រវាញទឹកដីខេត្តកោះកុង និងមួយចំនួនទៀតស្ថិតនៅតាមតំបន់ទន្លេស្រែពកក្នុងទឹកដីខេត្តមណ្ឌលគិរី។ នេះបើតាមការលើកឡើងរបស់មន្ត្រីនៃអង្គការមូលនិធិសាកលសម្រាប់ធម្មជាតិ(WWF)។

កញ្ញា MILOU Groenenbrg ប្រធានផ្នែកតាមដាននិងអ្នកស្រាវជ្រាវជីវចម្រុះនៃអង្គការWWFបានឱ្យដឹងថា នៅដងទន្លេស្រែពកនិងភ្នំព្រេចខេត្តមណ្ឌលគិរីគេបានប្រទះឃើញដានវត្តមានសត្វក្រពើភ្នំ។

កញ្ញាបានបន្តថា៖«សត្វក្រពើភ្នំជាប្រភេទសត្វដែលអៀនច្រើន ហេតុនេះគេកម្រឃើញវាដោយផ្ទាល់ភ្នែកណាស់។ ដោយហេតុនេះដើម្បីដឹងថាវាពិតជាមានវត្តមាននៅកម្ពុជានោះគេចាំបាច់ត្រូវតាមដានពីដានជើង, រូងរបស់វារស់នៅឬក៏លាមករបស់សត្វប្រភេទនេះជាចាំបាច់»។

កញ្ញាថា យ៉ាងណាក្តីសម្រាប់ស្លាកស្នាមនិងអត្តសញ្ញាណដែលគេដឹងថាសត្វប្រភេទនេះពិតជាមានវត្តមានពិតឬក៏អត់នោះមានភាពងាយស្រួលដោយសារស្លាកស្នាមរបស់វាមានភាពច្បាស់លាស់និងងាយស្រួលចំណាំផង។

ក្នុងឆ្នាំ២០២១នេះអង្គការនេះនឹងធ្វើការ សិក្សាស្រាវជ្រាវឱ្យបានទូលំទូលាយជាងឆ្នាំកន្លងមកដើម្បីអភិរក្សក៏ដូចជាស្តារនូវពូជសត្វប្រភេទនេះឱ្យកាន់តែមានច្រើននៅកម្ពុជា និងដើម្បីឱ្យបានដឹងច្បាស់លាស់ថា សត្វប្រភេទនេះមានប៉ុន្មានក្បាលហើយវាមានវត្តមាននៅទីណាខ្លះនៅកម្ពុជា។

កញ្ញា MILOU Groenenbrg បានបន្តឱ្យដឹងថា ចំពោះការប្រឈមនៃសត្វក្រពើភ្នំមានដូចជាការប្រមាញ់យកស្បែក ការនេសាទខុសច្បាប់ ការនេសាទដោយខ្សែភ្លើងឆក់ និងការរកពងក្រពើភ្នំពីសំណាក់ពលរដ្ឋអ្នកស្រុកជាដើម។ ក្រៅពីការបាត់បង់ទីជម្រក ការដែលសត្វក្រពើប្រភេទនេះបង្កាត់ពូជជាមួយសត្វក្រពើដទៃទៀតដែលធ្វើឱ្យពូជរបស់វាលែងសុទ្ធដូចកាលពីមុន។

ជាមួយគ្នានេះដែរលោកនេត្រភក្ត្រារដ្ឋលេខាធិការក្រសួងបរិស្ថាន បានថ្លែងថា សត្វដ៏កម្រដែលប្រឈមនឹងការបាត់បង់ពូជពិសេសសត្វក្រពើភ្នំ និងសត្វស្លាបប្រភេទសត្វឱ្សប សត្វត្រយ៉ងយក្ស សត្វត្មាតនោះ រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាក្រសួងបរិស្ថានបានរួមសហការជាមួយដៃគូដោយមានវិធានការមួយដែលគេកំពុងធ្វើដើម្បីអភិរក្សក្នុងនោះវិធានការនៃការបង្កាត់ពូជដើម្បីបង្កើនបរិមាណសត្វកម្រនេះ និងលែងចូលធម្មជាតិ ដើម្បីរក្សានូវនិរន្តរភាពនៃវត្តមានសត្វ កម្រដែលជិតផុតទាំងអស់នៅកម្ពុជា។

លោកបានថ្លែងថា៖ «ចំពោះវិធានការបង្កាត់ពូជនេះ គឺគេបានចាប់ផ្តើមធ្វើមានដូចជាកន្ធាយក្បាលកង្កែប អណ្តើកហ្លួងជាដើម។ ក្រសួងបរិស្ថានមើលឃើញពីភាពចាំបាច់ក្នុងកិច្ចការពារសត្វប្រភេទមួយចំនួនដែលជិតផុតពូជ ឬក៏ជាការគំរាមកំហែងបំផុតនៅលើពិភពលោកនេះ ដូចជាសត្វក្រពើភ្នំដែលសំបូរច្រើននៅក្នុងប្រទេសកម្ពុជា»។

លោកថា ក្រៅពីនេះដូចជាសត្វទន្សោង រមាំងសត្វឱ្សប នៅប្រទេសកម្ពុជាក៏មានចំនួនច្រើនជាងគេផងដែរ។ហេតុនេះដើម្បីកិច្ចការពារសត្វទាំងនេះឱ្យនៅគង់វង្សតទៅមុខទៀតនោះក្រសួងចាំបាច់ត្រូវសហការជាមួយដៃគូរ អ្នកជំនាញដើម្បីរៀបចំនូវវិធានការផ្សេងៗក្នុងការរក្សានិរន្តភាពនៃសត្វប្រភេទនេះឱ្យគង់វង្សនៅកម្ពុជា។

ចំណែកលោក សេង ទៀក នាយកអង្គការ WWF បានឱ្យដឹងផងដែរថា ការប្រឈមមុខបាត់បង់ពូជសត្វក្រពើភ្នំមានច្រើនកត្តាក្នុងនេះដូចជាក្នុងអំឡុងក្នុងឆ្នាំ២០០៣ ដល់២០០៥ ប្រជាពលរដ្ឋបាននាំគ្នាមកប្រមូលពងរបស់វានៅតាមតំបន់ទន្លេស្រែពក ប៉ុន្តែបន្ទាប់ពីតំបន់ទន្លេស្រែពកនេះត្រូវបានគេដាក់បញ្ចូលជាតំបន់អភិរក្សធនធានធម្មជាតិស្ទួលមកសកម្មភាពនេះបានលុបបំបាត់ទៅវិញ។

លោកមានប្រសាសន៍ថា៖«កាលពីមុនសត្វក្រពើភ្នំនេះមិនត្រូវបានគេចាប់អារម្មណ៍ទេ ប៉ុន្តែទើបតែឆ្នាំ២០១៩គេបានស្គាល់ពីសត្វប្រភេទនេះជាក់លាក់ ហើយបានធ្វើការសិក្សាស្រាវជ្រាវនិងបានអភិរក្សសត្វប្រភេទកម្រនេះឡើង»។

ជាមួយគ្នានេះលោកថ្លែងអំណរគុណដល់ដៃគូរពាក់ព័ន្ធពិសេសក្រសួងបរិស្ថានដែលបានចូលរួមកិច្ចសហការក្នុងកិច្ចការពារអភិរក្សសត្វកម្រៗនៅកម្ពុជាក៏ដូចជាពិភពលោកនិងពិសេសសត្វក្រពើភ្នំដែលជាសត្វកម្របំផុតក្នុងលោកឱ្យគង់វង្សនៅកម្ពុជា៕

# អន្ទាក់ចាប់សត្វព្រៃចំនួន ជាង ៤៣.០០០ ត្រូវបានបង្ក្រាបក្នុងឆ្នាំ២០២០



*អត្ថបទ៖ ផល សុផានិត*

អន្ទាក់ដែលត្រូវបាន ដោះបានចេញពីតំបន់ការពារធម្មជាតិក្នុងឆ្នាំ២០២០ មានចំនួន ៤៣.២៧០អន្ទាក់ ដែលចំនួននេះមានការកើនឡើងជិត ៤០០០អន្ទាក់ ខណៈឆ្នាំ២០១៩ អន្ទាក់ដែលត្រូវបានមន្ត្រីឧទ្យានុរក្សនិងសហគមន៍តំបន់ការពារធម្មជាតិដោះបានចំនួន ៣៩.៣៨២ អន្ទាក់។

នៅឆ្នាំ ២០២០កន្លងទៅ រថយន្តចំនួន ២១៥ គ្រឿងដែលប្រព្រឹត្តបទល្មើសត្រូវបានរឹបអូស និងគោយន្តចំនួន ៦១១ គ្រឿង ព្រមទាំងម៉ូតូចំនួន ៥៩០ គ្រឿងត្រូវបានដកហូតផងដែរ ។ មន្ត្រីឧទ្យានុរក្សក៏បានដកហូតកាំភ្លើងកែច្នៃដែលប្រើសម្រាប់បរបាញ់សត្វបានចំនួន ៧៣៧ ដើម និងដកហូតឈើបានចំនួន ២៧១៨ម៉ែត្រគូប។

ក្រសួងបរិស្ថានបង្ហាញនូវមោទកភាពចំពោះមន្ត្រីឧទ្យានុរក្ស សមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិនិងអង្គការដៃគូទាំងអស់ដែល បានចូលរួមការ គ្រប់គ្រងនិងអភិរក្សតំបន់ ការពារធម្មជាតិនៅក្នុងឆ្នាំ២០២០ កន្លងមកនេះជាពិសេសក្នុងការអនុវត្តច្បាប់ទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ដោយបានបទល្មើសដែលបង្ក្រាប បាននៅឆ្នាំ២០២០ មានកំណើនចំនួន ៣៤៤២ករណី ឬកើនឡើងប្រមាណ ៣០ភាគរយ។

នេះគឺជាការថ្លែងរបស់លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការនិងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាននៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ដោយបានបង្ហាញពីប្រសិទ្ធភាពកាន់តែខ្ពស់នៃការអនុវត្តច្បាប់ប្រឆាំងនឹងបទល្មើសក្នុង តំបន់ការពារធម្មជាតិនិងរបៀងអភិរក្សជីវៈចម្រុះទាំង ៦៨ កន្លែង ដែលស្ថិតនៅក្រោម ការការពារ និងអភិរក្សរបស់ក្រសួងបរិស្ថាន។

លោករដ្ឋលេខាធិការ នេត្រ ភក្ត្រា បានឱ្យដឹងថា នៅពេញមួយឆ្នាំ២០២០ មន្ត្រីឧទ្យានុរក្សទាំង ១២០០ នាក់នៃក្រសួងបរិស្ថានបានចុះល្បាតសរុបចំនួន ២៧.៥៨៨ លើក ខណៈនៅការចុះល្បាតនៅឆ្នាំ ២០១៩ មានចំនួន ២៤.០៤៨ លើក ពោលគឺមានការចុះល្បាតមានការកើនឡើងចំនួន ៣.៥៤០ លើក។

ក្នុងការចុះល្បាតនេះ មន្ត្រី ឧទ្យានុរក្សដែលជាមន្ត្រីនគរបាលយុត្តិធម៌បានបង្ក្រាបបទល្មើសបានចំនួន ៨.៩១៧ ករណី ខណៈឆ្នាំ ២០១៩ បង្ក្រាបបានបទល្មើសធនធានធម្មជាតិចំនួន ៥.៤៧៥ ករណីគឺមានការកើនឡើងចំនួន ៣.៤៤២ ករណី។ តាមការបញ្ជាក់របស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងបរិស្ថាន បទល្មើសដែលបង្ក្រាបបានភាគច្រើនជាបទល្មើសលួចកាប់ឈើ ការរុករានទន្ទ្រានកាន់កាប់ដីព្រៃខុសច្បាប់ ការបរបាញ់សត្វ និងការដាក់អន្ទាក់ចាប់សត្វ។

លោក នេត្រ ភក្ត្រា បានថ្លែងថា៖ «ការបង្ក្រាបនិងទប់ស្កាត់បទល្មើសមានការកើនឡើង បានបង្ហាញពីការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធភាព និងបង្ហាញពីការខិតខំរបស់មន្ត្រីឧទ្យានុរក្សសហគមន៍តំបន់ការពារធម្មជាតិ និងអ្នកពាក់ព័ន្ធដោយមិនខ្លាចនឿយហត់ក្នុងការចុះល្បាតការពារព្រៃឈើនិងជីវៈចម្រុះ»។

ក្រសួងបរិស្ថានបានថ្លែងថា នៅឆ្នាំ ២០២០ កន្លងទៅ សំណុំរឿងបទល្មើសធនធានធម្មជាតិដែលត្រូវបានបញ្ជូនទៅកាន់តុលាការមានចំនួន ៦០៥ ករណី ហើយនៅឆ្នាំ ២០២០ មានការផាកពិន័យអន្តរការណ៍លើជនប្រព្រឹត្តល្មើសចំនួន ៨៥៧ ករណី និងបទល្មើសដែលត្រូវធ្វើការអប់រំនិងធ្វើកិច្ចសន្យាមានចំនួន ២៩៤៦ ករណី។

លោក នេត្រ ភក្ត្រា បានបន្ថែមថា ក្នុងប្រតិបត្តិការចុះល្បាតនិងបង្ក្រាបបទល្មើស នៅឆ្នាំ២០២០ មន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថានបានរឹបអូស រណាយន្តបានចំនួន ៤.០០៤ គ្រឿង គឺមានការកើនឡើងប្រមាណ ៥០០ គ្រឿង ខណៈនៅឆ្នាំ ២០១៩ រណាយន្តដែលត្រូវបានរឹបអូសមានចំនួន ៣.៤៩៤ គ្រឿង។

លោករដ្ឋលេខាធិការក្រសួងបរិស្ថានបានថ្លែងថា ជាមួយប្រសិទ្ធភាពនៃការអនុវត្តច្បាប់នេះ បទល្មើសព្រៃឈើខ្នាតធំលែងមានទៀតហើយ គឺនៅមានបទល្មើលព្រៃឈើខ្នាតតូចដែលមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថាននិងបន្តសហការជាមួយសហគមន៍តំបន់ការពារធម្មជាតិ និងអង្គការដៃគូបន្តអប់រំផ្សព្វផ្សាយច្បាប់ និងអនុវត្តន៍ច្បាប់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសបន្តទៀតដើម្បីថែរក្សា និងការពារធនធានធម្មជាតិដែលកម្ពុជានៅមាននេះឱ្យបានគង់វង្សសម្រាប់មនុស្សរាប់ជំនាន់ទៅមុខទៀត»៕

# សេដ្ឋកិច្ចកម្ពុជានឹងងើបឡើងវិញ ក្នុងរង្វង់៤ភាគរយនៅឆ្នាំ២០២១



*សំណង់អគារការិយាល័ និងសណ្ឋាគារទំនើបថ្មីៗកំពុងមានការវិវឌ្ឍក្នុងទីក្រុងភ្នំពេញ។ **ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភ្នំពេញ***

*អត្ថបទ៖ ផល សុផានិត*

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក វង្សី វិស្សុត បានព្យាករណ៍ពីសេដ្ឋកិច្ចកម្ពុជាថា ក្នុងឆ្នាំ២០២១នេះ សេដ្ឋកិច្ចកម្ពុជា នឹងងើបឡើងវិញ ក្នុងរង្វង់៤ភាគរយ។

ការស្ទុះងើបឡើងវិញ ក្នុងកំណើនគួរឲ្យកត់សំគាល់នេះ ត្រូវបានលោក វង្សី វិស្សុត បង្ហាញថា ដោយសារតែការខិតខំប្រឹងប្រែង និងការអន្តរាគមន៍យ៉ាងខ្លាំងក្លា របស់រដ្ឋាភិបាលកម្ពុជា។

ការបញ្ជាក់របស់លោក វង្សី វិស្សុត ធ្វើឡើងក្នុងឱកាសអញ្ជើញចូលរួមក្នុងកម្មវិធី វេទិកាសាធារណៈ ស្តីពី «គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១» របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្សព្វផ្សាយឱ្យទូលំទូលាយ ដល់សាធារណជន ស្វែងយល់លំអិត ពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២១ នៅព្រឹកថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១នេះ។

> ការអន្តរាគមន៍របស់រាជរដ្ឋាភិបាលនេះ ពិតជាផ្តល់ផលល្អដល់ការស្តារសេដ្ឋកិច្ច និងល្អចំពោះលំនឹងជីវភាពរស់នៅរបស់ប្រជាជន និងការថយចុះនៃការធ្លាក់ក្នុងភាពក្រីក្រ

លោក វង្សី វិស្សុត បានឲ្យដឹងថា ៖«ឆ្នាំ២០២១នេះ សេដ្ឋកិច្ចកម្ពុជាងើបឡើងវិញក្នុងរង្វង់៤ភាគរយ ងើបគ្រប់វិស័យទាំងអស់ ការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរង្វង់៤ភាគរយនេះ មិនមែនជាកំណើនអាក្រក់នោះទេ ជាកំណើនមួយដែលស្ទុះងើបពី-៣.១ភាគរយ [២០២០]។ តែទោះជាយ៉ាងណាខ្ញុំមិនហ៊ានព្យាករណ៍ ឲ្យខ្ពស់ជាងនេះនោះឡើយ ដោយសារតែវិបត្តិភ្ញៀវទេសចរ បញ្ហានៃជំងឺកូវីដ១៩ ធ្វើឲ្យវិស័យទេសចរណ៍ធ្លាក់ចុះខ្លាំង ហើយសម្រាប់ឆ្នាំ២០២១ នេះ ក៏មិនអាចដឹងឡើយថា វិស័យទេសចរណ៍ មានដំណើរការល្អប្រសើរឡើងវិញឬអត់»។

លោកបានបន្តថា សេដ្ឋកិច្ចកម្ពុជា មួយចំណែកធំបានមកពីវិស័យទេសចរណ៍ ដូច្នេះប្រសិនបើវិស័យទេសចរណ៍ជាប់គាំង កម្ពុជាពិបាកនឹងងើបឡើងវិញនៃសេដ្ឋកិច្ច។ កត្តាមួយទៀត គឺតម្រូវការនៃការនាំចេញផលិតកម្មកម្ពុជា ទៅទីផ្សារអន្តរជាតិ។ កម្ពុជាខ្លាចថា នៅពេលដែលមានការយឺតយ៉ាវនៃការងើបឡើងវិញ នៃសេដ្ឋកិច្ចពិភពលោក ការនាំចេញរបស់កម្ពុជា ក៏យឺតយ៉ាវដូចគ្នា។

មន្ត្រីជាន់ខ្ពស់រូបនេះបញ្ជាក់ថា ការហ៊ានអះអាងពីកំណើនសេដ្ឋកិច្ច ក្នុងរង្វង់៤ភាគរយក្នុងឆ្នាំនេះ ដោយសារតែកម្ពុជា បានទទួលការអន្តរាគមន៍យ៉ាងកក់ក្តៅពីប្រមុខរាជរដ្ឋាភិបាលសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ក្នុងការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ ក្នុងពេលដែលពិភពលោក ពិសេសកម្ពុជាកំពុងជួបវិបត្តិនៃជំងឺកូវីដ១៩នេះ។

រាជរដ្ឋាភិបាលកម្ពុជា បានអន្តរាគមន៍លើវិស័យផ្សេងៗជាច្រើន ដើម្បីទប់ស្កាត់ការធ្លាក់ចុះនៃសេដ្ឋកិច្ចកម្ពុជា។ ក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះត្រឹម-៣.១ភាគរយប៉ុណ្ណោះ ខណៈក្នុងតំបន់អាស៊ានធ្លាក់ចុះ-៣.៣ភាគរយ។

លោក វង្សី វិស្សុត បានឲ្យដឹងថា ដោយសារតែការអន្តរាគមន៍ពី ប្រមុខរាជរដ្ឋាភិបាល ទាំងផ្នែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩, ការផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យម (SME), ការបន្ធូរបន្ថយពន្ធព្រមទាំងការចូលរួមដោះស្រាយរូបិយវត្ថុមួយចំនួន របស់ធនាគារជាតិនៃកម្ពុជា បានរួមចំណែកផ្តល់ភាពងាយស្រួលដល់ការប្រកបអាជីវកម្ម ការរកស៊ីរបស់វិនិយោគិន។

លោកបានបន្ថែមថា ដោយសារតែការអន្តរាគមន៍ដ៏វិសេសវិសាល របស់ថ្នាក់ដឹកនាំកម្ពុជា ធ្វើឲ្យកំណើនសេដ្ឋកិច្ចកម្ពុជា មានក្នុងចន្លោះ-៣.១ភាគរយ មិនធ្លាក់ដល់៥ភាគរយ។

មន្ត្រីជាន់ខ្ពស់រូបនេះបន្ថែមថា យោងតាមរបាយការណ៍របស់អង្គការ UNDP ឲ្យដឹងថា ប្រសិនបើកម្ពុជាមិនមានអន្តរាគមន៍ ហើយអន្តរគមន៍មិនមានប្រសិទ្ធភាពម្ល៉េះពេលនេះសេដ្ឋកិច្ចកម្ពុជា នឹងឈានធ្លាក់ដល់-៤.១ភាគរយ មិនស្ថិតក្នុងកំណើន -៣.១ភាគរយនោះឡើយ។

លោក វង្សី វិស្សុត ឲ្យដឹងទៀតថា ប្រសិនបើគ្មានការអន្តរាគមន៍ ការគាំពារសង្គម ការផ្តល់ជំនួយសង្គម, ការបង្កើតការងារតាមជនបទនោះទេ ភាពក្រីក្ររបស់កម្ពុជា នឹងធ្លាក់ដល់១៧ភាគរយ ប៉ុន្តែបន្ទាប់ពីមានការជ្រោមជ្រែង ធ្វើឲ្យភាពក្រីក្រកម្ពុជា ស្ថិតក្នុងចន្លោះ១៤ភាគរយប៉ុណ្ណោះ។ ចំណែកឯភាពអត់ការងារធ្វើក៏ធ្លាក់ចុះពី៤.៨ភាគរយ មកត្រឹម៤.១ភាគរយ។

លោកបានបញ្ជាក់ថា៖ «ការអន្តរាគមន៍របស់រាជរដ្ឋាភិបាលនេះ ពិតជាផ្តល់ផលល្អដល់ការស្តារសេដ្ឋកិច្ច និងល្អចំពោះលំនឹងជីវភាពរស់នៅរបស់ប្រជាជន និងការថយចុះនៃការធ្លាក់ក្នុងភាពក្រីក្រ»។

មន្ត្រីជាន់ខ្ពស់រូបនេះបញ្ជាក់ថា ឧស្សាហកម្មកាត់ដេររបស់កម្ពុជាធ្លាក់ពី-៦.៧ភាគរយ មក -៦.៤ភាគរយ ការនាំចេញលើវិស័យកាត់ដេររបស់កម្ពុជាធ្លាក់ចុះ ១០ភាគរយ ប៉ុន្តែវិស័យកាត់ដេរកើន២៦ភាគរយ។ ដូច្នេះការនាំចេញរបស់កម្ពុជា ធ្លាក់ចុះត្រឹមតែ-១ភាគរយប៉ុណ្ណោះ។

សម្រាប់វិស័យកសិកម្មក្នុងឆ្នាំ ២០២០ បានរួមចំណែក ០.៥ ភាគរយនៃសេដ្ឋកិច្ចកម្ពុជា ខណៈការនាំចេញផលិតផលកសិកម្មបានកើនឡើង១៨ភាគរយ៕

# កម្ពុជានឹងជំរុញដំណាំដំឡូងមី ទៅជាមាសសម្រាប់ការនាំចេញ

*អត្ថបទ៖ ផល សុផានិត*

លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានឲ្យដឹងថា គោលនយោបាយជាតិស្តីពី «ដំឡូងមី» ២០២០-២០២៥ មានគោលបំណងធ្វើឲ្យកម្ពុជាក្លាយជាទីតាំងផលិតកែច្នៃ និងជាអ្នកផ្គត់ផ្គង់ផលិតផលដំឡូងមីប្រកបដោយភាពជឿទុកចិត្តសម្រាប់ជំរុញការនាំចេញទៅទីផ្សារពិភពលោក។

ក្នុងពិធីសម្ពោធជាផ្លូវការនូវគោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ លោក ប៉ាន សូរស័ក្តិ បានថ្លែងថា គោលនយោបាយជាតិស្តីពី ដំឡូងមី ២០២០-២០២៥ ត្រូវបានណែនាំឲ្យបង្កើតឡើងនៅក្នុងឯកសារគម្រោងកម្មវិធីពិពិធកម្ម និងពង្រីកការនាំចេញពីកម្ពុជា ដំណាក់កាលទីពីរ ផ្នែកដំឡូងមី (CEDEP II) និងមានចែងនៅក្នុងផែនការ សកម្មភាពយុទ្ធសាស្រ្ត សមាហរណកម្ម ពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨ ។

គោលនយោបាយជាតិនេះ មានគោលបំណងធ្វើឲ្យប្រទេសកម្ពុជា ក្លាយជាទីតាំងផលិតកែច្នៃ និងជាអ្នកផ្គត់ផ្គង់ផលិតផលដំឡូងមីមួយ ប្រកបដោយភាពជឿទុកចិត្ត សម្រាប់ជំរុញការនាំចេញទៅទីផ្សារពិភពលោក និងមានគោលដៅសំខាន់ចំនួន៣គឺ ទី១ ការផ្លាស់ប្តូរពីផលិតកម្មដំឡូងមី បែបប្រពៃណីឬគ្រួសារឱ្យទៅជាផលិតកម្មដំឡូងមី បែបពាណិជ្ជកម្ម។

គោលបំណងទី២គឺ ការគាំទ្រដល់អ្នកកែច្នៃផលិតផលដំឡូងមី ឱ្យមានសក្តានុពល និងទាក់ទាញវិនិយោគដើម្បីកែច្នៃផលិតផលពីដំឡូងមី ដែលមានតម្លៃបន្ថែមខ្ពស់សម្រាប់ផ្គត់ផ្គង់ទីផ្សារ និងទី៣ ការលើកកម្ពស់ភាពប្រកួតប្រជែង ពាណិជ្ជកម្ម តាមរយៈការជ្រៀតចូល និងចាប់យកចំណែកទីផ្សារដោយផ្សារភ្ជាប់ទៅនឹងអន្តរវិស័យ ដែលពាក់ព័ន្ធក្នុងការនាំចេញ។

លោក ប៉ាន សូរស័ក្តិ លើកឡើងថា តាមរយៈការវិភាគ ដំណាំដំឡូងមីត្រូវបានគេរកឃើញថា បានចូលរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

លោកបានមានប្រសាសន៍ថា៖ «ហេតុនេះដើម្បីទាញយកសក្តានុពលនេះ កម្ពុជាគួរតែធ្វើឱ្យប្រសើរឡើងនូវខ្សែប្រវាក់តម្លៃរបស់ខ្លួន ដោយពង្រឹងសមត្ថភាពដែលមានស្រាប់ និងបង្កើតសមត្ថភាពថ្មី ដើម្បីចាប់យកកាលានុវត្តភាពទីផ្សារដែលកំពុងរីកចម្រើនសម្រាប់ កំណើនសេដ្ឋកិច្ចរួម និងពង្រីកសេដ្ឋកិច្ច របស់ខ្លួន ក្នុងការចូលរួម ដើម្បីសម្រេចគោលដៅ របស់រាជរដ្ឋាភិបាល កម្ពុជាឆ្នាំ២០៣០ និង២០៥០»។

ជាក់ស្តែងនៅក្នុងឆ្នាំនេះ ការប្រមូលផល និងការផ្គត់ផ្គង់មើមដំឡូងមីស្រស់ ចូលទីផ្សារពិភពលោកមានចំនួនរហូតទៅដល់១២លានតោន ដែលជាពិសេស គឺស្ថិតនៅក្នុងតំបន់អាស៊ីខាងកើត ដែលក្នុងចំណែកនៃការផ្គត់ផ្គង់ទីផ្សារទាំងនេះ កម្ពុជាជាប្រទេសផលិតដំឡូងមីដ៏ធំ ដែលស្ថិតនៅលំដាប់ទី៤នៅក្នុងតំបន់អាស៊ី និងលំដាប់ទី១០នៅក្នុងពិភពលោក។

លោករដ្ឋមន្ត្រី បានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំថា គោលនយោបាយជាតិនេះគឺជាការចាប់ផ្តើមនៃដំណើរថ្មី មួយសម្រាប់ប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍវិស័យកសិ-ពាណិជ្ជកម្ម ដែលនឹងនាំមកនូវកំណើនសេដ្ឋកិច្ចបន្ថែមប្រកបដោយបរិយាបន្នដល់កម្ពុជា ក្នុងបរិបទប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងគាំទ្រដល់ផែនការរបស់រាជរដ្ឋាភិបាល ឆ្ពោះទៅកាន់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅពេលខាងមុខ។

ដំឡូងមី បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ជីវភាពប្រជាជននៅតាមទីជនបទ និងបង្កើតការងារថ្មី ក៏ដូចជាអភិវឌ្ឍន៍វិជ្ជាជីវៈនៅក្នុងការដាំដុះ ការប្រមូលផល ការកែច្នៃ សម្រាប់ការនាំចេញ។ ជាពិសេសវាជាដំណាំកសិ-ពាណិជ្ជកម្មសម្រាប់ការនាំចេញ និងមិនមែនជាអាហារមូលដ្ឋាន សម្រាប់ចិញ្ចឹមជីវិត របស់ប្រជាជនកម្ពុជាឡើយ ប៉ុន្តែវាជាដំណាំសំខាន់បំផុតបន្ទាប់ពីស្រូវ ពោត និងស្រូវសាលី ហើយត្រូវបានដាំដុះដោយប្រជាកសិករនៅតាមទីជនបទ និងបានក្លាយទៅជាដំណាំសក្តានុពល ដោយសារតំបន់ដាំដុះ និងបរិមាណនៃផលិតផល មានការពង្រីកច្រើនឡើងៗ យ៉ាងឆាប់រហ័ស៕



# ប្រជាពលរដ្ឋសំដែងការព្រួយបារម្ភអំពីការកើនឡើងតម្លៃម្ហូបអាហារនៅក្នុងអំឡុងពេលកូវីដ១៩

*អត្ថបទ៖ អរិយបុត្រ*

ប្រជាជនកម្ពុជាកំពុងតែត្អូញត្អែរថា ដោយសារជំងឺរាតត្បាតឆ្លងរាលដាលកូវីដ១៩ លុយងាយស្រួលក្នុងការចំណាយ ប៉ុន្តែវាពិបាកក្នុងការរកចំណូលមែនទែន។

ស្ត្រីមេផ្ទះមួយរូបឈ្មោះ កាន ចាន់ណា អាយុ៣៤ឆ្នាំបាននិយាយហើយរអ៊ូថា លុយដែលមានចំនួន២០ ម៉ឺនរៀលឬ៥០ដុល្លារនៅក្នុងកាបូបវាមិនងាយស្រួលទេក្នុងការចំណាយទៅលើថ្លៃម្ហូបអាហារ ដែលលោកស្រីគ្រោងនឹងចូលផ្សារដើរទិញសម្រាប់ទុករយៈពេលមួយសប្តាហ៍ឡើយ។

លោកស្រីបាននិយាយនៅពេលកំពុងដើរផ្សារច្បារអំពៅថា ពីមុនលោកស្រីចំណាយមិនដល់៥០ ដុល្លារទេក្នុងមួយសប្តាហ៍ដើម្បីទិញបន្លែ សាច់ ស៊ុត ត្រី ផ្លែឈើ និងគ្រឿងផ្សំខ្លះសម្រាប់សមាជិកគ្រួសារ ៥ នាក់របស់លោកស្រីនៅក្នុងរយៈពេល១សប្តាហ៍ ប៉ុន្តែពេលនេះភាគច្រើន៥០ដុល្លារគឺមិនគ្រប់គ្រាន់ឡើយ គឺមានតែលើសពី៥០ដុល្លារ ទៅជិត៨០ដុល្លារ ក៏មានដែរពេលខ្លះ ។

លោកស្រីបានបន្ថែមថា៖ «ឥឡូវនេះធ្វើការមួយខែបានប្រាក់ខែត្រឹមតែ ៣០០ ទៅ ៤០០ ដុល្លារក្នុងមួយខែប៉ុន្តែសូមស្រមៃមើលជាង ៦០ ដុល្លារក្នុងមួយសប្តាហ៍តើយើងអាចតស៊ូដើម្បីរស់បានយ៉ាងដូចម្តេច?»។

អ្នកស្រី កាន ចាន់ណា អាចមកពីគ្រួសារវណ្ណៈកណ្តាលមួយនៅក្នុងរាជធានីភ្នំពេញ ប៉ុន្តែអ្នកស្រី ស៊ាន រ័ត្នអាយុ៤៥ឆ្នាំជាអ្នកសំអាតនៅក្រុមហ៊ុនមួយបាននិយាយថា រាល់ថ្ងៃគ្រួសាររបស់លោកស្រីដែលមានសមាជិក៦នាក់អាចមានលទ្ធភាពចំណាយទៅលើ អាហារតិចជាង ៥ ដុល្លារក្នុងមួយថ្ងៃ។

អ្នកស្រីរ័ត្នបាននិយាយថា៖«ពួកយើងនៅពេលនេះមិនដែលបានទិញរបស់ល្អទៅញ៉ាំទេ ពេលខ្លះខ្ញុំទិញកូនត្រីតូចៗនិងបន្លែទៅស្លម្ជូរព្រលឹត ត្រកួនហូបគ្រាន់តែចម្អែតពោះប៉ុណ្ណោះ ហើយពេលខ្លះទៅឆាបន្លែជាមួយនឹងសាច់ជ្រូកបីជាន់ និងសាច់យាវគោបន្តិចបន្តួចប៉ុណ្ណោះ»។



*ស្ត្រីមេផ្ទះកំពុងចំអិនម្ហូបអាហារសម្រាប់គ្រួសារប្រចាំថ្ងៃ។ **ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកភ្នំពេញ***

មុនពេលជំងឺកូវីដ១៩ ជំងឺរាតត្បាត លោក សុខ ភេន អាយុ ៤០ ឆ្នាំជាអ្នកបើកឡាំប្រីតាឥណ្ឌាមួយរូប បាននិយាយថា ប្រាក់ចំណូលពីសេវាកម្មរបស់គាត់នៅពេលយប់ចាប់ពីម៉ោង ៥ ល្ងាចដល់ ៥ ព្រឹកគឺល្អណាស់ជាមួយចំណូលពី ២០ ដុល្លារទៅ ៣០ ដុល្លារក្នុងមួយថ្ងៃ ប៉ុន្តែឥឡូវមិនអាចទទួលបានលើសពី ១០ ដុល្លារទេ។

លោកបន្ថែមថា៖ «ឥឡូវខ្ញុំរត់ ជាង១៥ ម៉ោងក្នុងមួយថ្ងៃចាប់ពីពេលថ្ងៃត្រង់រហូតដល់ម៉ោង ៥ ព្រឹកខ្ញុំអាចទទួលបានប្រហែល ១៥ដុល្លារប៉ុណ្ណោះ»។

លោកបានដាក់ជាសំនួរថា "តើខ្ញុំអាចដេកយ៉ាងម៉េចបាន? ខ្ញុំត្រូវបង់រំលោះតុក តុក របស់ខ្ញុំទៅធនាគារនៅថ្ងៃជីវភាពប្រចាំថ្ងៃទៀត ។ ខ្ញុំត្រូវរកប្រាក់ចំណូលយ៉ាងហោចណាស់ ៥០០ ដុល្លារក្នុងមួយខែ។ លុយឥឡូវពិបាករកណាស់ តែចាយវិញមហាស្រួល"។

ក្រៅពីតម្លៃម្ហូបអាហារនិន្នាការថ្មីនៃការឡើងថ្លៃប្រេងសាំងនៅក្នុងប្រទេសក៏ធ្វើឱ្យប្រជាជនមានការព្រួយបារម្ភផងដែរ។ ឥឡូវនេះតម្លៃហ្គាសមួយលីត្រ ២,១០០ រៀល, ប្រេងម៉ាស៊ូតគឺ ៣០០០ រៀល ប្រេងសាំងធម្មតា ៣.៣៥០ រៀល និងស៊ុបពែ គឺ៣,៨៥០ រៀល ។

ទាក់ទងនឹងតម្លៃម្ហូបអាហារនេះ អង្គការយូនីហេស្វ ថ្មីៗនេះក៏បានចេញនូវរបាយការណ៍មួយផងដែរ ដោយអះអាងថា «ការវាយតម្លៃរហ័សរបស់អង្គការសហប្រជាជាតិលើផលប៉ះពាល់សង្គមសេដ្ឋកិច្ច ដែលបង្កឡើងដោយជំងឺកូវីដ១៩ នៅកម្ពុជា» បានរកឃើញថាទោះជាលទ្ធភាពទទួលបានអាហារមិនរងផលប៉ះពាល់ធ្ងន់ធ្ងរក៏ដោយ ប្រជាជនត្រូវបង្ខំចិត្តប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់មួយចំនួន ដូចជាខ្ចីស្បៀងគេ កាត់បន្ថយបរិមាណអាហារសម្រាប់ហូបចុក និងពឹងផ្អែកកាន់តែខ្លាំងជាងមុនលើជម្រើសអាហារដែលមានតម្លៃថោក។

អង្គការនេះបានបន្តថា តម្លៃស្បៀងមានការកើនឡើងក្នុងឆ្នាំ២០២០ ជាពិសេសតម្លៃសាច់ ស៊ុត និងផលិតផលសាច់ត្រី នៅទីក្រុងភ្នំពេញ និងតម្លៃបន្លែស្រស់ នៅផ្សារតាមបណ្តាខេត្តនានា។ ផលប៉ះពាល់ទាំងនេះបង្កឱ្យមានការព្រួយបារម្ភជាងគេចំពោះសមាជិកគ្រួសារងាយរងគ្រោះ ជាពិសេសស្ត្រីមានផ្ទៃពោះ និងកុមារ។

គ្រួសារក៏ត្រូវប្រើប្រាស់យុទ្ធសាស្ត្រទប់ទល់ដែលរឹតតែបង្កផលប៉ះពាល់ ក្នុងរយៈពេលវែង ដូចជាកាត់បន្ថយការចំណាយលើសេវាចាំបាច់សំខាន់ៗ ដូចជាសេវាអប់រំនិងសុខភាព ការលក់ទ្រព្យសម្បត្តិដែលមានប្រយោជន៍សម្រាប់ផលិតភាព និងបញ្ជូនសមាជិកគ្រួសារទៅរកការងារធ្វើនៅខេត្តផ្សេងទៀតជាដើម។

ទោះបីជាយ៉ាងណាក៏ដោយអង្គការនេះក៏ទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ។

ពាក់ព័ន្ធនឹងការព្រួយបារម្ភនេះ នៅក្នុងសន្និបាតបូកសរុបការងារប្រចាំឆ្នាំរបស់ធនាគារជាតិកាលពីពេលថ្មីៗនេះលោកយូរុស្ស៊ីអគ្គនាយករងបច្ចេកទេស និងជា ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជា បានថ្លែងថា នៅឆ្នាំ២០២០តម្លៃម្ហូបអាហារបានកើនឡើង៤,៦ ភាគរយ ខណៈដែលកាលពីឆ្នាំ២០១៩ គឺត្រឹមតែ ២,១ភាគរយ ប៉ុណ្ណោះ ដោយសារកំណើនតម្រូវការ និង ការរអាក់រអួលក្នុងការដឹកជញ្ជូនទំនិញនាំចូល ស្របពេលដែលថ្លៃម្ហូបអាហារនៅប្រទេសសំខាន់ៗដែល កម្ពុជានាំចូលក៏បានកើនឡើងផងដែរ ។

លោកបានបន្តថា ប៉ុន្តែសម្រាប់ឆ្នាំ២០២១ នេះ កំណើនថ្លៃម្ហូបអាហារថមថយមកវិញ ដោយសារការថយចុះនៃការរំពឹងទុកពីកំណើនថ្លៃ និងភាពប្រសើរឡើងនៃការផ្គត់ផ្គង់ ស្របពេលដែលសន្ទស្សន៍ថ្លៃក្រុមម្ហូប អាហារមានកម្រិតខ្ពស់ស្រាប់នៅឆ្នាំ២០២១។

លោកបានបញ្ជាក់ថា អតិផរណាសម្រាប់ឆ្នាំ២០២១ នេះត្រូវបានព្យាករណ៍ថា គឺមានកម្រិត២,៩ ភាគរយ ដូចគ្នានឹងឆ្នាំ២០២០៕

## មួយខែដំបូងឆ្នាំ២០២១ ការនាំអង្ករថយចុះជាង ៣២ភាគរយ

*អត្ថបទ៖ ផល សុផានិត*

ក្នុងរយៈពេល១ខែដំបូងដើមឆ្នាំ ២០២១ នេះ កម្ពុជានាំអង្ករចេញទៅកាន់ទីផ្សារអន្តរជាតិ បានចំនួន ៣៤, ០៣២ តោនប៉ុណ្ណោះ ឃើញថា ថយចុះ ១៦,១៧៧ តោន ឬស្មើនឹង ៣២,០៧ ភាគរយ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញផ្សាយថា ការនាំអង្ករចេញរបស់កម្ពុជា សឹងតែគ្រប់ទិសដៅមានការថយចុះ លើកលែងតែ ប្រទេសចិនមានកំណើន៧,៧ ភាគរយ។ គោលដៅប្រទេសក្នុងតំបន់អឺរ៉ុប ថយ ៥៩ ភាគរយ។ ប្រទេសក្នុងតំបន់អាស៊ាន ថយ៤៤,៦១ ភាគរយ និងប្រទេសដទៃផ្សេងទៀត ថយចំនួន ៣៤,០៣ ភាគរយ។

របាយការណ៍ដដែលបន្តទៀតថា អង្កររបស់កម្ពុជាបានធ្វើការនាំចេញទៅកាន់ ប្រទេសចំនួន២៨ ក្នុងនោះប្រទេសចិនឈរលំដាប់ថ្នាក់លេខ១ ចំនួន ១៦,១៦៣ តោន។ ប្រទេស១៤ ក្នុងតំបន់អឺរ៉ុប ចំនួន៧,៦៣៥តោន ប្រទេសចំនួន២ក្នុងតំបន់អាស៊ាន ចំនួន ៣,២៥៩តោន និងប្រទេស១១ ផ្សេងទៀត ចំនួន ៧,២១៦ តោន។

កាលពីឆ្នាំ២០២០ កម្ពុជានាំអង្ករចេញបានចំនួន ៦៩០,៨២៩ តោន កើនឡើង១១,៤០ ភាគរយ




*អង្ករប្រភេទផ្សេងៗដែលបានដាក់តាំងលក់នៅក្នុងទីផ្សារនាពេលបច្ចុប្បន្ន។ **រូបភាព៖ សហការី***




*លោកនាយករដ្ឋមន្ត្រីថៃលោកប្រាយុទ្ធចាន់អូចា (កណ្តាល) និងរដ្ឋមន្ត្រីអាស៊ានក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី ៥១ (AEM៥១) នៅទីក្រុងបាងកកប្រទេសថៃ កាលពីឆ្នាំ២០១៩ កន្លងទៅ។ **រូបភាព៖ Vietnam News***

# អាស៊ាន ជាតំបន់នៃប្រព័ន្ធតម្លៃសង្គមចម្រុះ
## ខុសពីតំបន់នានា ប៉ុន្តែគួរយកចិត្តទុកដាក់លើបញ្ហាក្រមសីលធម៌

*អត្ថបទ៖ អរិយបុត្រ*

បញ្ញវន្តនានានៅក្នុងតំបន់អាស៊ានបានអះអាងថា អាស៊ានគឺជាតំបន់មួយដែលពោរពេញទៅដោយធនធានចម្រុះនិងមានប្រព័ន្ធតម្លៃសង្គមចម្រុះខុសពីតំបន់នានានៅលើពិភពលោក ប៉ុន្តែតម្លៃនៃការអនុវត្តនិងស្វែងយល់ពីក្រមសីលធម៌គួរតែត្រូវពង្រឹង។

តម្លៃនៃប្រព័ន្ធសង្គមបែបនេះត្រូវបានគេលើកឡើងនៅក្នុងកម្មវិធីសិក្ខាសាលាតាមអនឡាញមួយដែលបានរៀបចំឡើងដោយ បណ្តាញសាកលវិទ្យាល័យអាស៊ាន (ASEAN University Network) កាលពីពេលថ្មីៗកន្លងទៅនេះ។






*លោកបណ្ឌិត ចូលទីស ឌីរ៉ាឌីធី (Choltis Dhirathiti) នាយកប្រតិបត្តិនៃបណ្តាញសាកលវិទ្យាល័យអាស៊ាម។ **រូបភាព៖ ASEAN***

នៅក្នុងកម្មវិធីនេះ បណ្តាបញ្ញវន្តនានាបានអះអាងថា អាស៊ានគឺជាតំបន់មួយដែលមានប្រព័ន្ធតម្លៃចម្រុះភាពខុសគ្នាខាងភូមិសាស្ត្រនយោបាយនិងសង្គមក៏ដូចជាភាពខុសគ្នានៃសេដ្ឋកិច្ចផងដែរ។

ពួកគេបានអះអាងថា ស្ថានភាពចម្រុះបែបនេះបានក្លាយជាការប្រកួតប្រជែងសម្រាប់តំបន់ដោយផ្តល់នូវទស្សនៈវិស័យខុសគ្នា វាបានបង្ហាញឱ្យឃើញថាអាស៊ានជាប្រភពនៃការប្រកួតប្រជែងក្នុងការបង្កើតអត្តសញ្ញាណអាស៊ានដ៏ស្អិតរមួតមួយ។

នៅក្រោមប្រធានបទ «ក្រមសីលធម៌ជាក់ស្តែងនៅក្នុងអាស៊ាន៖ បញ្ហាប្រឈមនិងអាទិភាពថ្មីៗសម្រាប់សកម្មភាពនៅក្នុងតំបន់» បណ្តាអ្នកដែលចូលរួមជាតំណាងសាកលវិទ្យាល័យនានាគឺបានពិភាក្សាអំពីបញ្ហាប្រឈមនៃក្រមសីលធម៌នៅក្នុងតំបន់អាស៊ានក្នុងវិស័យជាច្រើនដោយសារប្រព័ន្ធតម្លៃខុសគ្នានិងដើម្បីលើកកម្ពស់ការយោគយល់គ្នាសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់។

លោកបណ្ឌិត ប៉ូល លីម សាស្ត្រាចារ្យផ្នែកឥរិយាបទនិងធនធានមនុស្សមកពីសាកលវិទ្យាល័យ គ្រប់គ្រងសិង្ហបុរី លី កុងឆាន ( Singapore Management University Lee Kong Chian) បានអះអាងថា អនុលោមតាមអាទិភាពយុទ្ធសាស្ត្រនៃការរីកចម្រើនរបស់សកលវិទ្យាល័យឆ្ពោះទៅឆ្នាំ២០២៥ សាកលវិទ្យាល័យបានព្យាយាមបង្ហាញភាពជាអ្នកដឹកនាំខាងគំនិតរបស់ខ្លួនក្នុងការស្វែងយល់ស៊ីជម្រៅអំពីសេដ្ឋកិច្ចនយោបាយ និងសង្គមនៅអាស៊ី។

លោកបានអះអាងថា យុវជនអាស៊ានសម័យបច្ចុប្បន្ននេះមិនមានទំនោរច្រើនទៅលើបញ្ហានយោបាយរហូតដល់រំជួលចិត្តដូចដែលអ្នកដឹកនាំបែបប្រពៃណីនិងបទពិសោធន៍ពីមុនៗធ្លាប់មាននោះទេ ប៉ុន្តែពួកគេមានតម្លៃនិងគំនិតដែលពួកគេបានគិតដែលយើងគួរតែឲ្យពួកគេយកចែករំលែកគំនិតដើម្បីបង្កើននូវកិច្ចសហការនៅអាស៊ានទាំងមូលប្រកបដោយក្រមសីលធម៌។

លោកបានអះអាងថា លោកពិតជាមិនបានយល់ពីយុវជនអាស៊ានអស់នោះទេ ប៉ុន្តែយុវជនអាស៊ានមានតម្លៃដើម្បីសិក្សាស្វែងយល់ពីពួកគេច្រើន។ លោកបានបន្តថា ៖ «ប្រសិនបើយើងចំណាយពេលស្វែងយល់អំពីពួកគេនិងឲ្យពួកគេស្វែងយល់ជាមួយយើង យើងនឹងដឹងថាវិធីនិងគំនិតផ្សេងៗនឹងមាន សម្រាប់បញ្ហាប្រឈមនាពេលអនាគត»។

លោកបានសង្កត់ធ្ងន់ថា៖ «យុវជនអាស៊ាននឹងត្រូវការ ការសិក្សាដែលមានការចូលរួមស្វែងយល់ច្រើនពីគ្រប់ភាគី ប៉ុន្តែខ្ញុំសូមជំរុញឱ្យអង្គការនិងរដ្ឋាភិបាលអនុញ្ញាតឱ្យយុវជនរបស់យើងបង្ហាញផ្លូវឆ្ពោះទៅមុខវាគឺជាកាតព្វកិច្ចសីលធម៌របស់យើងក្នុងការធ្វើដូច្នេះ»។

លោកបណ្ឌិត ចូលទីស ឌីរ៉ាឌីធី (Choltis Dhirathiti) នាយកប្រតិបត្តិនៃបណ្តាញសាកលវិទ្យាល័យអាស៊ាម បានថ្លែងពីបទពិសោធន៍របស់លោកនៅក្នុងវិស័យឧត្តមសិក្សាហើយ បានចែករំលែកការសង្កេតរបស់លោកថា យុវជនអាស៊ានពិតជាមានការគិតនិងគំនិតជាច្រើនប៉ុន្តែក្រមសីលធម៌ គឺជាគំនិតមួយដែលគួរតែមាន។

លោកបានអះអាងថា ក្រម សីលធម៌គឺជាផ្នែកមួយនៃចក្ខុវិស័យបេសកកម្មនិងគុណតម្លៃស្នូលរបស់សាកលវិទ្យាល័យភាគច្រើន។ កម្មវិធីដែលផ្តល់សញ្ញាប័ត្រជាច្រើនមានគោលបំណងបង្វឹកនិស្សិតដែលបញ្ចប់ការសិក្សាប្រកបដោយក្រមសីលធម៌ ហើយបញ្ហាប្រឈមគឺត្រូវបង្ហាញចេតនាល្អទៅកាន់កន្លែងធ្វើការនៅពេលនិស្សិតបញ្ចប់ការសិក្សា។ វាគ្មិនផ្សេងទៀតមកពីសាកលវិទ្យាល័យអន្តរជាតិរួមមានអ្នកជំនាញផ្នែកក្រមសីលធម៌ក៏បានជំរុញឲ្យយុវជន អាស៊ានយកចិត្តទុកដាក់លើបញ្ហាក្រមសីលធម៌នេះផងដែរ៕

# ក្រសួងបីស្វះស្វែងបង្កើនសកម្មភាពសហគមន៍ទេសចរណ៍ប្រកបដោយនិរន្តរភាព



អ្នកទេសចរធ្វើដំណើរផ្សងព្រេងកម្សាន្តនៅក្នុងតំបន់ខ្នងផ្សារ។ រូបភាព៖ ហ្វេសប៊ុកក្រសួងបរិស្ថាន

*អត្ថបទ៖ អរិយបុត្រ*

រដ្ឋមន្ត្រីក្រសួងចំនួន៣ បង្ហាញនូវសុទិដ្ឋិនិយមនិងគាំទ្រអ្នកដែលពាក់ព័ន្ធជាពិសេសវិស័យឯកជនបង្កើនការរៀបចំ កញ្ចប់ទស្សនកិច្ចទៅកាន់តំបន់សហគមន៍ ខណៈវិស័យនេះបន្តរងសំពាធដោយសារតែវិបត្តិនៃការរីករាលដាលនៃមេរោគកូវីដ១៩ ។

ក្រសួងទាំងនេះមានក្រសួងទេសចរណ៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន បានជំរុញលើកទឹកចិត្ត និងគាំទ្រដល់វិស័យឯកជន ពិសេសទីភ្នាក់ងារទេសចរណ៍កម្ពុជាត្រូវបង្កើនការរៀបចំកញ្ចប់ទស្សនកិច្ចឱ្យបានច្រើនទៅកាន់តំបន់សហគមន៍នានានៅកម្ពុជា ដើម្បីចូលរួមជួយដោះស្រាយជីវភាពប្រជាពលរដ្ឋមូលដ្ឋាន ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ និងក្រោយវិបត្តិនេះ។

លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានលើកឡើងថា កម្ពុជាសម្បូរទៅដោយសក្តានុពលធម្មជាតិនិងអេកូទេសចរណ៍នៅទូទាំងប្រទេសរាប់ចាប់ពីតំបន់ឆ្នេរសមុទ្រដែលជាសមាជិក «ក្លិបឆ្នេរសមុទ្រដែលស្អាតបំផុតលើសាកលលោក» តំបន់ជួរភ្នំក្រវាញរួមបញ្ចូលទាំងតំបន់អារ៉ែង តំបន់បឹងទន្លេសាប និងតំបន់ភូមិភាគឦសានដែលមានសត្វផ្សោតដ៏កម្រជាដើម។

លោកបានបន្តថា៖ «ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ-១៩ ចលនាទេសចរណ៍ផ្ទៃក្នុងទៅកាន់តំបន់អេកូទេសចរណ៍ សហគមន៍ទេសចរណ៍ និងតំបន់ទេសចរណ៍ផ្សងព្រេង កាន់តែមានសន្ទុះកើនឡើងខ្លាំង បង្កើតបានជាប្រាក់ចំណូលដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងសហគមន៍ និងបានធ្វើឲ្យវិស័យអេកូទេសចរណ៍ និងសហគមន៍ទេសចរណ៍មានភាពធន់នឹងវិបត្តិរួមចំណែកទ្រទ្រង់ដល់វិស័យទេសចរណ៍ជារួម ពិសេសកាត់បន្ថយផលប៉ះពាល់នៃការធ្លាក់ចុះចំនួនភ្ញៀវទេសចរអន្តរជាតិ»។

នាឱកាសនោះ លោក វេង សាខុននិងលោកសាយ សំអាល់ បានបង្ហាញការគាំទ្រយ៉ាងពេញទំហឹងចំពោះការជំរុញលើកទឹកចិត្ត និងគាំទ្រដល់វិស័យឯកជន ពិសេសទីភ្នាក់ងារទេសចរណ៍កម្ពុជាបង្កើនការរៀបចំកញ្ចប់ទស្សនកិច្ចឱ្យបានច្រើនទៅកាន់តំបន់សហគមន៍នានានៅកម្ពុជា ដើម្បីចូលរួមជួយដោះស្រាយជីវភាពប្រជាពលរដ្ឋមូលដ្ឋាន ក្នុងដំណាក់កាលវិបត្តិជំងឺកូវីដ១៩ និងដំណាក់កាលក្រោយវិបត្តិនេះ។

លោក វេង សាខុន បានឲ្យដឹងផងដែរថា បច្ចុប្បន្ននៅកម្ពុជាក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម មានសហគមន៍នេសាទចំនួន ១៣១ ក្នុងចំណោមសហគមន៍នេសាទទាំងអស់៥១៦ ។ ទាំងនេះមានសក្តានុពលអាចបង្កើតជាសហគមន៍ទេសចរណ៍ធម្មជាតិ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិជាចម្បង។

លោកថា ៖ «ជាក់ស្តែង សហគមន៍នេសាទចំនួន ២៧ បាននិងកំពុងដំណើរការទេសចរណ៍ធម្មជាតិនៅតំបន់មាត់សមុទ្រ និងតំបន់បឹងទន្លេសាបនៅក្នុងខេត្តមួយចំនួនរួមមានខេត្តក្រចេះ ស្ទឹងត្រែង តាកែវ សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង បន្ទាយមានជ័យ កំពត ព្រះសីហនុ កែប និងខេត្ត កោះកុង»។

លោក វេង សាខុន បានបន្តថា ក្រសួងបង្កើតសហគមន៍ព្រៃឈើនៅទូទាំងប្រទេសសរុបចំនួន ៦៣៨ ក្នុងនោះបានធ្វើផែនការគ្រប់គ្រងចំនួន១០៣ ព្រមទាំងមានតំបន់ព្រៃឈើតាមបណ្តោយដងស្ទឹង ព្រែក បឹង ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចម្ការឈើដាំ ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ចម្ការកសិ-រុក្ខកម្ម ចម្ការរុក្ខទិវាថ្នាក់ជាតិ និងក្រោមជាតិ ដែលអាចអភិវឌ្ឍទៅជាគោលដៅទេសចរណ៍ធម្មជាតិ កសិ-ទេសចរណ៍ និងតំបន់លំហែកម្សាន្តផងដែរ។

សម្រាប់ លោក សាយ សំអាល់ បានឱ្យដឹងថា ក្រសួងបរិស្ថាន បានបង្កើតសហគមន៍មូលដ្ឋាននៅតំបន់ការពារធម្មជាតិមានចំនួន ១៧៤ នៅទូទាំងប្រទេសកម្ពុជា ក្នុងចំណោមនោះមានសហគមន៍ការពារធម្មជាតិ និងតំបន់ការពារធម្មជាតិជាង ២០ កំពុងមានសកម្មភាពទេសចរណ៍។

រដ្ឋមន្ត្រីបរិស្ថានលោក សាយ សំអាល់ បានថ្លែងថា ការអភិវឌ្ឍអេកូទេសចរណ៍ដែលឈរលើគោលការណ៍និរន្តរភាពបរិស្ថាន ព្រមទាំងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងការបែងចែកផលសេដ្ឋកិច្ចប្រកបដោយសមធម៌ មិនត្រឹមតែរួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកយ៉ាងសំខាន់ដល់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍដោយចីរភាពផងដែរ។

លោក សេង ទៀក ជានាយកអង្គការ WWF កម្ពុជាបានលើកឡើងថា ប្រទេសកម្ពុជាបានទទួលពរជ័យជាប្រេទសមួយដែលសម្បូរណ៍ព្រៃឈើ សត្វព្រៃ និងជីវៈចម្រុះជាច្រើនប្រភេទដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំបំផុត សម្រាប់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋាន និងសេដ្ឋកិច្ចជាតិ ប៉ុន្តែក្នុងបរិបទ «ធម្មជាតិ និងទេសចរណ៍» កម្ពុជានៅមិនទាន់ទាញយកឲ្យអស់សក្តានុពលនិងអត្ថប្រយោជន៏នៅឡើយទេពីសម្បត្តិធម្មជាតិទាំងនេះ។

លោកបានបញ្ជាក់ថា៖ «ខ្ញុំបាទអាចលើកឡើងថា វិស័យទេសចរណ៍ធម្មជាតិនៅកម្ពុជាគឺជាគ្រាប់ពេជ្រដែលមិនទាន់ច្នៃនៅឡើយ»។

កាលពីឆ្នាំ២០២០ កន្លងទៅនេះ កម្ពុជាទទួលបានភ្ញៀវអន្តរជាតិ ១,៣១ លាននាក់ ថយចុះ ៨០% និងភ្ញៀវទេសចរផ្ទៃក្នុង ៩លាននាក់ ថយចុះ ២០% ។ ការថយចុះនេះគឺបណ្តាលមកពី វិបត្តិជំងឺកូវីដ-១៩ ៕








# កម្ពុជាបានចាប់ផ្ដើមចាក់វ៉ាក់សាំងកូវីដ១៩ «ស៊ីណូហ្វាម» ដែលជាជំនួយសម្បុរសធម៌ ពីសាធារណរដ្ឋប្រជាមានិតចិន

## ឥស្សរជនខ្មែរដំបូងចាក់មុនគេគឺលោក ហ៊ុន ម៉ាណែត

*អត្ថបទ៖ ផល សុផានិត*

ស្របពេលដែលពិភពលោកកំពុងប្រឈមមុខនឹងជំងឺសកលឬដែលគ្រប់គ្នាស្គាល់ថា វីរុសកូរ៉ូណាឬកូវីដ១៩នោះ ក្នុងឆ្នាំ២០២១នេះ វ៉ាក់សាំងជាច្រើនប្រភេទត្រូវបានក្រុមអ្នកវិទ្យាសាស្ត្រជាច្រើនប្រទេស រួមគ្នាស្រាវជ្រាវដើម្បីទប់ស្កាត់ការចម្លងជំងឺនេះ។

ថ្មីៗនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានឯកភាព យល់ព្រមទទួលយកវ៉ាក់សាំងបង្ការការចម្លងជំងឺកូវីដ១៩ ពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ចំនួន១លានដូសដែលត្រូវបានស្គាល់ឈ្មោះយ៉ាងច្បាស់ថា «ស៊ីណូហ្វាម» (Sinopharm) ដើម្បីធ្វើការចាក់ជូនប្រជាពលរដ្ឋកម្ពុជាមិនគិតថ្លៃនិងដោយឈរលើគោលការស្ម័គ្រចិត្ត។

វ៉ាក់សាំងប្រឆាំងមេរោគកូវីដ១៩ នៅពេលបច្ចុប្បន្ននេះមានច្រើន ដែលត្រូវបានប្រទេសមួយចំនួនទទួលស្គាល់ ហើយត្រូវបានចាក់ជូនប្រជាពលរដ្ឋរបស់ពួកគេ ដូចជា វ៉ាក់សាំងរបស់ប្រទេសរុស្ស៊ី ចិន អាមេរិក អឺរ៉ុប ហើយថ្មីៗនេះគឺប្រទេសឥណ្ឌា។ វ៉ាក់សាំងទាំងនោះត្រូវបានទទួលស្គាល់ និងទទួលយកចាក់ជូនប្រជាពលរដ្ឋតាមឥទ្ធិពលនយោបាយ និងតាមធនធាន ព្រមទាំងតាមភូមិសាស្ត្រ ប៉ុន្តែសម្រាប់កម្ពុជា ជំហរដែលប្រមុខរាជរដ្ឋាភិបាល ដែលមានសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែនបានប្រកាសគឺ «កម្ពុជាទទួលស្វាគមន៍គ្រប់វ៉ាក់សាំងទាំងអស់ ឱ្យតែវ៉ាក់សាំងនោះមានសុវត្ថិភាពពិតប្រាកដ ហើយដាច់ខាតមិនយកប្រជាពលរដ្ឋកម្ពុជាសម្រាប់ពិសោធន៍ឡើយ»។

លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល បានថ្លែងថា វ៉ាក់សាំងស៊ីណូហ្វាម (Sinopharm) ត្រូវបានបែងចែករួចទៅហើយនៅលើពិភពលោក ក្នុងនោះប្រទេសប៉ាគីស្ថានប្រហែល៨៨លានដូស។ សម្រាប់ប្លុកខាងមជ្ឈឹមបូព៌ាមានរហូតដល់៧៥លានដូស ដោយឡែកប្រទេសឥណ្ឌូនេស៊ី ប្រហែល៧០លានដូស។

លោកស្រីបញ្ជាក់ថា ៖ «វ៉ាក់សាំងនេះ ត្រូវបានប្រើប្រាស់រួចទៅហើយប្រហែលជាចូលចំនួនខ្ទង់លានអ្នកឯណោះ និងមានប្រសិទ្ធភាពរហូតដល់៧៩.៣៤ ភាគរយ»។

វ៉ាក់សាំងស៊ីណូហ្វាម (Sinopharm) គឺជាវ៉ាក់សាំង ផ្ដល់ជូនដោយប្រទេសចិន ហើយកម្ពុជាទទួលយកដោយឈរលើមូលហេតុមួយចំនួន ដូចជា ការរក្សាទុកវ៉ាក់សាំងទាំងនេះមានសភាពងាយស្រួល ខណៈដែលសីតុណ្ហភាពត្រូវរក្សាទុកសមស្របជាមួយនឹងអាកាសធាតុរបស់កម្ពុជា នោះគឺស្ថិតនៅក្នុងសីតុណ្ហភាព២ដល់៨អង្សារក្រោមសូន្យ ប្រៀបធៀបទៅនឹងវ៉ាក់សាំងនៃប្រទេសមួយចំនួនគឺស្ថិតនៅក្នុងសីតុណ្ហភាព៧០អង្សាក្រោមសូន្យ ដែលហួសពីសមត្ថភាពនៃការគ្រប់គ្រងរបស់កម្ពុជា ប៉ុន្តែយោងតាមប្រសាសន៍សម្ដេចតេជោ កាលពីចុងឆ្នាំ២០២០ ក្រសួងសុខាភិបាលកម្ពុជាក៏បាន និងកំពុងសាងសង់ឃ្លាំងសម្រាប់ស្តុកវ៉ាក់សាំងផងដែរ ដែលអាចរក្សាទុករហូតដល់៨០អង្សារក្រោមសូន្យ។ ក្រៅពីនេះ ការដឹកជញ្ជូនក៏នឹងងាយស្រួលជាងការដឹកពីប្រទេសចិន មកកាន់ព្រះរាជាណាចក្រកម្ពុជាផងដែរ។

លោកស្រី ឱ វណ្ណឌីន បន្ថែមថា ៖«ឆ្លងតាមការប្រើប្រាស់វ៉ាក់សាំងនេះ មិនទាន់ឃើញមានរបាយការណ៍ណាមួយឬក៏ព័ត៌មានណាមួយដែលបញ្ជាក់ថា វ៉ាក់សាំងនេះមានប្រតិកម្មឬបញ្ហាធំដុំសម្រាប់ប៉ះពាល់ លើសុខភាពមនុស្សនៅឡើយនោះទេ មានបន្តិចបន្តួចរឿងក្តៅខ្លួន វាជាការធម្មតា







,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,។ រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី

ព្រោះវាប្រតិកម្មនៃវ៉ាក់សាំង នៅពេលដែលយើងចាក់ចូលទៅក្នុងខ្លួនមនុស្សឬក៏មានការក្រហមស្បែកឬឈឺនៅកន្លែងចាក់វាមានតិចតួច ប៉ុន្តែវានឹងបាត់ទៅវិញនៅប៉ុន្មានម៉ោងក្រោយ ឬមួយថ្ងៃក្រោយ»។

នៅដំណាក់កាលដំបូង វ៉ាក់សាំងស៊ីណូហ្វាមចំនួន ៦០ម៉ឺនដូសបានមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃទី០៧ ខែកុម្ភៈ។ វ៉ាក់សាំងដំបូងនេះម្ជុលទី១ ត្រូវបានចាក់ជូនកូនប្រុសច្បងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន គឺលោកហ៊ុន ម៉ាណែត កាលពីថ្ងៃទី១០ ខែកុម្ភៈ ដែលជាថ្ងៃបើកយុទ្ធនាការនៃការចាប់ផ្តើមចាក់វ៉ាក់សាំងកូវីដ១៩ស៊ីណូហ្វាមដែលជាជំនួយសម្បុរសធម៌របស់សាធារណរដ្ឋប្រជាមានិតចិន។

ក្រសួងសុខាភិបាល បានបញ្ជាក់ដែរថា អាយុដែលអាចចាក់បានគឺមានពី១៨ឆ្នាំ ទៅ៥៩ឆ្នាំ ហើយអ្នកដែលមានអាយុលើសពី ៦០ឆ្នាំ ត្រូវរង់ចាំលទ្ធផលនៃការសិក្សាសិន។

សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានប្រកាសនៅថ្ងៃបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ក្នុងប្រទេសកម្ពុជាថា ទីបំផុត ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការជាផ្លូវការនូវការចាក់វ៉ាក់សាំងជូនប្រជាជនរបស់ខ្លួន ហើយ។




,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,។ រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី

សម្តេចហ៊ុន សែន បានមានប្រសាសន៍ថា ៖ «នេះជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិន ដែលជាមិត្តដែកថែប ដែលខ្ញុំសុំយកឱកាសនេះថ្លែងអំណរគុណចំពោះបក្ស រដ្ឋ កងទ័ព និងប្រជាជនចិន ពិសេស ឯកឧត្តមប្រធានាធិបតី ស៊ី ជិនភីង ដែលបានផ្តល់ជំនួយដ៏សប្បុរសដល់ប្រជាជនកម្ពុជា»។

> នេះជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិន ដែលជាមិត្តដែកថែប ដែលខ្ញុំសុំយកឱកាសនេះថ្លែងអំណរគុណចំពោះបក្ស រដ្ឋ កងទ័ព និងប្រជាជនចិន ពិសេស ឯកឧត្តមប្រធានាធិបតី ស៊ី ជិនភីង ដែលបានផ្តល់ជំនួយដ៏សប្បុរសដល់ប្រជាជនកម្ពុជា

នាយករដ្ឋមន្ត្រីកម្ពុជារូបនេះ បានបញ្ជាក់ថា មុនចាក់វ៉ាក់សាំង មានការលើកឡើងមួយចំនួនជុំវិញអវត្តមានរបស់លោកលើការចាក់វ៉ាក់សាំងនាថ្ងៃនេះ បណ្តាលមកពីកត្តាអាយុរបស់លោក រហូតប្រើពាក្យមិនសមរម្យខ្លះមកលើលោកទៀតផង។

សម្តេចហ៊ុន សែន បានសង្កត់ធ្ងន់ថា ៖ «ច្បាស់ណាស់! ថ្ងៃនេះ (ទី១០ ខែកុម្ភៈ) កូនប្រុសរបស់ខ្ញុំបានទទួលវ៉ាក់សាំងមុនគេជំនួសឱ្យឪពុក ដែលនេះក៏បញ្ជាក់ច្បាស់ពីការទទួលខុសត្រូវរបស់យើងចំពោះមុខជនរួមជាតិយើង»។

ប្រមុខរាជរដ្ឋាភិបាលដែលមានសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន ពាន ផ្តាំផ្ញើចំពោះបងប្អូនជនរួមជាតិទាំងក្នុងនិងនៅក្រៅប្រទេសឱ្យបានច្បាស់ថាកុំបារម្ភលើវ៉ាក់សាំងមកពីប្រទេសណា? ម៉ាកអ្វី? តែគប្បីបារម្ភពីការអត់វ៉ាក់សាំងចាក់ ព្រោះគ្មានវ៉ាក់សាំងលក់តាមផ្សារដូចលក់ត្រី លក់ត្រកួននោះទេ។

សម្តេចថា បងប្អូនខ្មែរដែលរស់នៅប្រទេសជឿនលឿនមួយចំនួនធំឬអាចដល់៩៨ភាគរយមិនទាន់បានទទួលការចាក់វ៉ាក់សាំងនៅឡើយ ព្រោះវាអត់មានវ៉ាក់សាំង បើទោះបីប្រទេសនោះមានលុយហើយក៏រកទិញវ៉ាក់សាំងមិនបាន ដោយសារការផលិតមិនទាន់។

លោកហ៊ុន ម៉ាណែត ដែលជាឥស្សរជនខ្មែរដំបូងទទួលការចាក់វ៉ាក់សាំងកូវីដ១ស៊ីណូហ្វាម បានថ្លែងឡើងថា ៖ «ខ្ញុំបានចាក់វ៉ាក់សាំងការពារកូវីដ១៩ រួចហើយ។ សូមបងប្អូនខ្មែររួមគ្នា និងត្រៀមលក្ខណៈចូលរួមជាមួយរដ្ឋាភិបាលអនុវត្តវិធានការសុខាភិបាល និងទទួលចាក់ថ្នាំបង្ការទៅតាមដំណាក់កាលនីមួយៗ តាមផែនការលទ្ធភាពរបស់រាជរដ្ឋាភិបាល ដើម្បីការពារខ្លួនយើង គ្រួសារយើង សង្គមជាតិយើង និងប្រជាជនយើងនៅក្នុងកាលៈទេសៈដ៏លំបាកនេះ ពីព្រោះការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ គឺផ្តើមចេញពីខ្លួនយើង ដើម្បីការពារខ្លួនយើង និងអ្នកដទៃ»។

លោកបានថ្លែងប្រាប់អ្នកសារព័ត៌មាននៅពេលចាក់វ៉ាក់សាំងនេះថា លោកមិនមានអារម្មណ៍ភ័យខ្លាចនោះទេ តែលោកសប្បាយចិត្តដែលបានចាក់វ៉ាក់សាំងការពារកូវីដនេះ ហើយលោកក៏បានអំពាវនាវទៅដល់ប្រជាពលរដ្ឋខ្មែរផ្សេងទៀត គួរមកទទួលការចាក់វ៉ាក់សាំងកូវីដ១៩នេះ។

លោកបានមានប្រសាសន៍បន្ទាប់ពីទទួលបានវ៉ាក់សាំងម្ជុលទី១រួចថា ៖ «ខ្ញុំបានចាក់វ៉ាក់សាំងការពារកូវីដ-១៩ រួចហើយ។ សូមបងប្អូនខ្មែររួមគ្នា និងត្រៀមលក្ខណៈចូលរួមជាមួយរដ្ឋាភិបាលអនុវត្តវិធានការសុខាភិបាល និងទទួលចាក់ថ្នាំបង្ការទៅតាមដំណាក់កាលនីមួយៗ តាមផែនការលទ្ធភាពរបស់រាជរដ្ឋាភិបាល ដើម្បីការពារខ្លួនយើង គ្រួសារយើង សង្គមជាតិយើង»។

លោកហ៊ុន ម៉ាណែតបន្តទៀតថា ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ គឺផ្តើមចេញពីខ្លួនយើង ដើម្បីការពារខ្លួនយើងនិងអ្នកដទៃ។

ស្ត្រីខ្មែរដែលទទួលនូវការចាក់វ៉ាក់បន្ទាប់ពីលោកហ៊ុន ម៉ាណែត គឺលោកស្រី យក់ សម្បត្តិ ជារដ្ឋលេខាធិការក្រសួងសុខាភិបាល។

លោកស្រីបានថ្លែងប្រាប់ដែរថា ៖ «ខ្ញុំមានអារម្មណ៍ធម្មតា ដោយសារខ្ញុំស្ម័គ្រចាក់វ៉ាក់សាំងនេះ ហើយខ្ញុំត្រូវធ្វើការច្រើនជាមួយនឹងកូវីដ និងខ្ញុំជាគ្រូពេទ្យនៅជួរមុខផងដែរ ដែលខ្ញុំត្រូវតែទទួលវ៉ាក់សាំងនេះជាចាំបាច់»។

គួរបញ្ជាក់ផងដែរថា សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់វ៉ាក់សាំងកូវីដ១៩ចំនួន១លានដូស ដែលដំបូងនេះវ៉ាក់សាំងចំនួន៦០ម៉ឺនដូសត្រូវបានដឹកមកដល់ប្រទេសកម្ពុជាកាលពីថ្ងៃទី០៧ ខែកុម្ភៈ ដោយក្នុងនោះ វ៉ាក់សាំងចំនួន៣០ម៉ឺនដូសសម្រាប់ក្រសួងសុខាភិបាល និង៣០ម៉ឺនដូសសម្រាប់ក្រសួងការពារជាតិ។

ការចាក់វ៉ាក់សាំងកូវីដ១៩ធ្វើឡើងក្នុងមន្ទីរពេទ្យចំនួន៤ ក្នុងនោះ នៅមន្ទីរពេទ្យកាល់ម៉ែត្រ សម្រាបឥស្សរជនជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ។ នៅមន្ទីរពេទ្យអង្គឌួង សម្រាប់ឥស្សរជនជាអនុរដ្ឋលេខាធិការ ឬមានឋានៈស្មើ។ សម្រាប់ឥស្សរជនជាអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តនឹងចាក់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ឯទីតាំងទី៤គឺនៅមន្ទីរពេទ្យកុមារជាតិសម្រាប់អ្នកសារព័ត៌មាន៕

# សង្គមស៊ីវិលស្នើរបញ្ឈប់ការចាប់ខ្លួនសកម្មជនតែក្រសួងថា ការអនុវត្តច្បាប់មិនលើកលែងជនល្មើសណាឡើយ

*អត្ថបទ៖ អមរិន្ទ ដានុត*

អង្គការសង្គមស៊ីវិល សមាគម និងសហគមន៍ជាង៧០ស្ថាប័នបានចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយដោយឱ្យក្រសួងបរិស្ថានគួរបញ្ឈប់ការចាប់ខ្លួននិងធ្វើទុក្ខបុកម្នេញសកម្មជនការពារព្រៃឈើ។

សេចក្តីថ្លែងការណ៍នេះធ្វើឡើងមួយថ្ងៃបន្ទាប់ពីសកម្មជនការពារព្រៃឈើនិងជា ម្ចាស់ពានរង្វាន់វីរជនការពារបរិស្ថានពិភពលោកឆ្នាំ២០១៦ លោក អ៊ួច ឡេង រួមនឹងសកម្មជន៤រូបទៀតត្រូវបានដោះលែងក្រោយពីមន្ត្រីបរិស្ថានឃាត់ខ្លួនមួយរយៈរហូតបញ្ជូនទៅតុលាការខេត្តក្រចេះផងដែរ។

ក្រុមអង្គការ សង្គមស៊ីវិលទាំងនេះ បានលើកឡើងថា ក្រសួងបរិស្ថានបានចោទប្រកាន់អ្នកទាំង៥នាក់ថា «បានចូលក្នុងតំបន់ការពារធម្មជាតិដោយគ្មានការអនុញ្ញាត»។ ការចោទប្រកាន់នេះធ្វើឡើងដោយគ្មានមូលដ្ឋានច្បាប់នៅកម្ពុជា។

សេចក្តីថ្លែងការណ៍រួមនេះបានសង្កត់ធ្ងន់ថា៖ «យើងខ្ញុំស្នើឱ្យក្រសួងបរិស្ថានបញ្ឈប់យុទ្ធនាការនៃការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសកម្មជនការពារព្រៃឈើនិងសមាជិកសហគមន៍នៅតាមមូលដ្ឋាន»។

សកម្មជនការពារព្រៃឈើទាំង៥នាក់ដែលត្រូវបានមន្ត្រីមូលដ្ឋានរបស់ក្រសួងបរិស្ថានឃាត់ខ្លួននោះរួមមាន លោកអ៊ួច ឡេង លោក ហេង ស្រស់ លោក ម៉ាន ម៉ាត់ លោក ហេង រ៉ុន និង លោក តង ជាង។ ពួកគាត់ត្រូវបានឃាត់ខ្លួនដោយគ្មានការចោទប្រកាន់អស់រយៈពេល៣យប់ នៅមន្ទីរបរិស្ថាននិងអធិការដ្ឋានក្រុងក្រចេះ មុនពេលត្រូវបានដោះលែងឱ្យមានសេរីភាពវិញនៅថ្ងៃទី០៨ ខែកុម្ភៈ។

សកម្មជនទាំង៥នាក់នេះត្រូវបានដោះលែងវិញ បន្ទាប់ពីផ្តិតមេដៃលើកិច្ចសន្យាដែលហាមឃាត់ពួកគាត់មិនឱ្យធ្វើសកម្មភាពអភិរក្សផ្សេងៗ នៅក្នុងតំបន់ការពារធម្មជាតិ ឬចែករំលែកវីដេអូ រូបភាព ឬព័ត៌មានឱ្យអង្គភាពខាងក្រៅ ប្រសិនបើគ្មានការអនុញ្ញាតពីអាជ្ញាធរ។

ក្រុមអង្គការ សហគមន៍ និងសមាគមទាំង៧៤ស្ថាប័ននេះ បានលើកឡើងថា ៖ «ការបដិសេធមិនឱ្យចូលទៅកាន់តំបន់ការពារធម្មជាតិគឺអាចធ្វើឡើងសម្រាប់តំបន់ជាក់លាក់ដែលបានកំណត់រួចហើយថាជាតំបន់ស្នូល ដែលព្រៃឡង់មិនទាន់ត្រូវបានកំណត់ទេ»។



ក្រុមទាំងនេះបានបន្តថា វាជារឿងដែលគួរឱ្យសោកស្តាយ ដែលនេះមិនមែនជាលើកទី១ទេដែលក្រសួងបរិស្ថានបានបដិសេធសកម្មជនការពារព្រៃឈើ មិនឱ្យចូលក្នុងដែនជម្រកសត្វព្រៃនេះដូចធម្មតា។

មិនត្រឹមតែជាសកម្មជនការពារព្រៃឈើទេ ប៉ុន្តែលោកអ៊ួច ឡេង ក៏ជាប្រធានអង្គការក្រុមកិច្ចការពិសេសសិទ្ធិមនុស្សកម្ពុជាផងដែរ។ លោកនិងសកម្មជន៤នាក់ផ្សេងទៀត ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី០៥ ខែកុម្ភៈ នៅចំណុចអូរស៊ែរ ភូមិអាជេន ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ។

លោក អ៊ួច ឡេង បានឱ្យដឹងថា លោកនិងសកម្មជនព្រៃឈើចំនួន៥នាក់ផ្សេងទៀតត្រូវបានសាលាដំបូងខេត្តក្រចេះដោះលែងឱ្យមានសេរីភាពវិញ បន្ទាប់ពីធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពមួយចំនួនក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ដែលត្រូវបានអាជ្ញាធរចាត់ទុកថាសកម្មភាពរបស់ពួកគាត់ខុសច្បាប់។

យោងតាមរបាយការណ៍របស់អង្គការអាដហុកបានឱ្យដឹងថា មូលហេតុនៃការឃាត់ខ្លួនដែលអង្គការនេះទទួលព័ត៌មានពីពលរដ្ឋសហគមន៍ គឺ ដោយសារតែក្រុមសកម្មជនការពារព្រៃឈើទាំងនេះ បានចូលទៅធ្វើសកម្មភាពដាក់ស្លាកជាពាក្យស្លោកលើដើមឈើ ក្នុងន័យឱ្យមានការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ និងចូលរួមក្នុងការការពារព្រៃឈើជាសម្បត្តិដូនតា។

គួរបញ្ជាក់ផងដែរថា ក្នុងរយៈពេលមិនដល់១ឆ្នាំផង លោក អ៊ួច ឡេង និងលោក ម៉ាន ម៉ាត់ ជាសកម្មជនការពារព្រៃឈើ ត្រូវបានឃាត់ខ្លួនជាលើកទី២ ដែលកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ កន្លងទៅ ជាមួយនឹងសកម្មជន២រូបទៀតគឺលោក ឃេម សុឃី និងលោក ស្រី ថី ដែលជាសកម្មជនការពារព្រៃឡង់ ខេត្តព្រះវិហារ។

ការិយាល័យអ្នកនាំពាក្យក្រសួងបរិស្ថានបានចេញសេចក្តីប្រកាសព័ត៌មានរបស់ខ្លួនផងដែរថា ជនទាំង៥នាក់នេះបានលួចធ្វើសកម្មភាពដោយខុសច្បាប់ ហើយមន្ត្រីឧទ្យានុរក្សជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានតួនាទីភារកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ អនុវត្តតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិក្នុងការទប់ស្កាត់និងបង្ក្រាបសកម្មភាពខុសច្បាប់ទាំងឡាយដែលប្រព្រឹត្តនៅក្នុងតំបន់ការពារធម្មជាតិ មិនថាជនណាឡើយ។

ការិយាល័យអ្នកនាំពាក្យក្រសួងបរិស្ថានបានបន្តថា ក្រុមអង្គការក្រុមកិច្ចការពិសេសសិទ្ធិមនុស្សកម្ពុជាបានធ្វើសកម្មភាពខុសច្បាប់ម្តងរួចមកហើយ និងត្រូវបានតុលាការតម្រូវឱ្យផ្អាកសកម្មភាពរហូតដល់លោក អ៊ួច ឡេង ប្រធានអង្គការនេះទៅចុះបញ្ជីអង្គការខ្លួននៅក្រសួងមហាផ្ទៃជាមុនសិន មុននឹងធ្វើសកម្មភាពបន្តទៀត។

លោកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើងដោយចោទជាសំណួរថាតើលើកទឹកចិត្តនិងផ្តល់លទ្ធភាពនោះមានន័យយ៉ាងណា បើអាជ្ញាធរជាញឹកញយនិងខណៈនេះបានឃាត់ខ្លួននិងចោទប្រកាន់ពលរដ្ឋ ហាមប្រាមសហគមន៍ចូលទៅតំបន់ការពារ។ លោកស្រីថា តំបន់ការពារ មិនគួរក្លាយជាតំបន់ហាមឃាត់នោះទេ ហើយច្បាប់ស្តីពីតំបន់ការពារឆ្នាំ២០០៨ គួរត្រូវបានកែសម្រួលដើម្បីឱ្យស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់កិច្ចការពារបរិស្ថានឆ្នាំ១៩៩៦ ដើម្បីបង្កភាពអំណោយផលដល់សហគមន៍អាចចូលរួមក្នុងកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ។

លោកស្រីបានថ្លែងថា ៖ «ខ្ញុំសូមកោតសរសើរដល់វីរភាពបុគ្គលទាំងឡាយ ទាំងមន្ត្រី សកម្មជនសហគមន៍ទាំងឡាយដែលចូលរួមពិតក្នុងបុព្វហេតុការពារធនធានធម្មជាតិ និងអំពាវនាវដល់អាជ្ញាធរគួរបញ្ឈប់ការរារាំង ចោទប្រកាន់ ឬដាក់ចេញនូវគោលការណ៍ដែលរឹតត្បិតផ្ទុយពីស្មារតីនៃរដ្ឋធម្មនុញ្ញនិងមាត្រា១នៃច្បាប់កិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ»។

លោកនេត ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថានបាននិយាយថាក្រុមអង្គការ សង្គមស៊ីវិលដែលអួតខ្លួនថាស្រឡាញ់យុត្តិធម៌ គោរពសិទ្ធិមនុស្ស គួររៀនទទួលស្គាល់ការពិត ហើយសូមកុំព្យាយាមការពារក្រុមជនដែលមិនគោរពច្បាប់ និងកុំបំពេញការងារបង្កប់ដោយរបៀបវារៈនយោបាយ ហើយគួរមានភាពស្មោះត្រង់ចំពោះការសហប្រតិបត្តិការ។

លោកបានបន្តថា យោងតាមចម្លើយសារភាពរបស់ក្រុមជនដែលអះអាងខ្លួនជាសកម្មជនបរិស្ថាននៅចំពោះមុខសមត្ថកិច្ចថាខ្លួនពិតជាបានលួចចូលនិងធ្វើសកម្មភាពក្នុងតំបន់ការពារធម្មជាតិគឺខុសច្បាប់ ហើយការលួចចូលក្នុងព្រៃឡង់គឺពួកគេធ្វើសកម្មភាពនិងថតរូបផ្សេងៗដើម្បីគៀគរថវិកាជំនួយ។

លោកនេត ភត្រា ប្រាប់ថា៖ «នេះបានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតនៃការធ្វើសកម្មភាពរបស់ពួកគេ និងគ្មានចេតនាសុច្ចរិតណាមួយក្នុងការការពារព្រៃឈើឱ្យពិតប្រាកដឡើយ គឺគ្រាន់តែដើម្បីស្វែងរកជំនួយប៉ុណ្ណោះ»។

អ្នកនាំពាក្យរូបនេះបន្តថា ក្រុមនេះបានលួចធ្វើសកម្មភាពក្រោមរូបភាពនៃអង្គការក្រៅរដ្ឋាភិបាលដែលគេដឹងថាមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃផងដែរ ហើយតុលាការបានណែនាំឱ្យក្រុមជននេះគោរពច្បាប់និងចុះបញ្ជីអង្គការបស់ខ្លួនតាមច្បាប់ផងដែរ។ ទង្វើទាំងនេះពិតជាគួរឱ្យខ្មាសអៀនបំផុត។

ក្រសួងបរិស្ថាននៅតែគូសបញ្ជាក់ពីការអនុវត្តច្បាប់ដោយមិនលើកលែងចំពោះជនល្មើសណាម្នាក់ឡើយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីប្រសិទ្ធភាពលើកិច្ចការពារនិងអភិរក្សធនធានធម្មជាតិដែលមាន៕

# កម្ពុជានិងកូរ៉េខាងត្បូង ចុះMoUបញ្ជូនពលករទៅបម្រើការងារលើកទី៦

*អត្ថបទ៖ អមរិន្ទ ដានុត*

រាជរដ្ឋាភិបាលកម្ពុជានិងសាធារណរដ្ឋកូរ៉េបានបន្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) លើកទី៦ ។

ការចុះហត្ថលេខាបន្តអនុស្សរណយោគយល់គ្នានេះ ត្រូវបានធ្វើឡើង នាថ្ងៃអង្គារ ទី០២ ខែកុម្ភៈ ឆ្នាំ២០២១នេះ រវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារ និងមុខរបរនៃសាធារណរដ្ឋកូរ៉េ។

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានឱ្យដឹងថា គិតចាប់ពីឆ្នាំ២០០៧មក កម្ពុជាបានបញ្ជូនពលករសរុបចំនួន ៦៨ ២៩៤នាក់ (ស្រី ១៤ ២៥៥នាក់) ក្នុង វិស័យឧស្សាហកម្ម កសិកម្ម និងសំណង់ ដែលអាណត្តិការងារមានរយៈពេល ៤ឆ្នាំ ១០ខែ។ បច្ចុប្បន្ន ពលករកម្ពុជាដែលកំពុងបម្រើការងារនៅសាធារណរដ្ឋកូរ៉េ មានចំនួនប្រមាណ ៤៥ ៤៦២នាក់ (ស្រី ១០ ១៨៣នាក់)។

លោកអ៊ិត សំហេងបានលើកឡើងថា៖ «តាំងពីចាប់ផ្តើមនៃការបញ្ជូនមក កម្ពុជាតែងតែជាប់ចំណាត់ថ្នាក់ល្អជាប្រទេសបញ្ជូន និងតាមរយៈការពិភាក្សារវាងភាគីកម្ពុជា-កូរ៉េ»។

លោកថា បន្ទាប់ពីស្ថានភាពកូវីដ១៩នៅសាធារណរដ្ឋកូរ៉េមានភាពធូរស្រាល ដែលអាចទទួលយកកម្លាំងពលកម្មបរទេសបាន កម្ពុជារំពឹងថានឹងក្លាយជាប្រទេសអទិភាពក្នុងការបញ្ជូន ដោយសារកម្ពុជាមានស្ថានភាពកូវីដ១៩ល្អប្រសើរ មានជើងហោះហើរច្រើន និងអត្រាពលករកម្ពុជាខុសច្បាប់មានកំរិតទាបបើធៀបជាមួយប្រទេសបញ្ជូនផ្សេងទៀត។

គួរបញ្ជាក់ផងដែរថា ការបញ្ជូនពលករកម្ពុជាទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) បានចុះអនុស្សរណៈនៃការយោគយល់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងឯកឧត្តម Roh Moo-Hyun អតីតប្រធានាធិបតីនៃសាធាណរដ្ឋកូរ៉េ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦ កន្លងមកដែលមាន គណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងមុខរបរនិងការងារនៃសាធារណរដ្ឋកូរ៉េ

# យុវជនមួយក្រុមទទួលជ័យលាភី កម្មវិធី «អាជីវកម្មខ្ញុំ» ពីក្រសួងអប់រំ

*អត្ថបទ៖ ផល សុផានិត*

ថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសលទ្ធផលនៃកម្មវិធីអាជីវកម្មខ្ញុំ ដែលក្នុងនោះមានបណ្តាក្រុមយុវជនជាច្រើនមកពីសកលវិទ្យាល័យនានា បានដាក់ពាក្យចូលរួមប្រកួត។ សម្រាប់ជ័យលាភីលេខមួយ បានទៅលើក្រុមយុវជនមកពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានកែច្នៃផលិតផលធម្មជាតិ ដែលបានដាំដុះនៅក្នុងប្រទេសកម្ពុជា ទៅជាសាប៊ូ។

សាប៊ូមានច្រើនប្រភេទណាស់ មានសាប៊ូទឹក សាប៊ូម្សៅ សាប៊ូដុំជាដើម។ ដោយឡែកសាប៊ូលាងចាន ក៏មានច្រើនប្រភេទច្រើនម៉ាកទាំងផលិតផលក្នុងស្រុក និងក្រៅស្រុក តួយ៉ាងជ័យលាភីលេខមួយនេះ គឺការកែច្នៃស្លឹកគទៅជាសាប៊ូលាងចាន។

កញ្ញា ខេង ឡាដា ជាសមាជិកម្នាក់ក្នុងចំណោមសមាជិកទាំង៦នាក់ របស់ក្រុមសាប៊ូលាងចានស្លឹកគ បានបង្ហាញក្តីរំភើប ចំពោះលទ្ធផលដែលទទួលបាននេះ។ តំណាងក្រុមជ័យលាភីរូបនេះបានរៀបរាប់ប្រាប់ ថា ៖«ខ្ញុំមិននឹកស្មានថា ក្រុមខ្ញុំបានជាប់លេខមួយអីចឹងទេ ក្រោយប្រកាសលទ្ធផលខ្ញុំរំភើបមែនទែន ព្រោះត្រូវប្រកួតប្រជែងច្រើនក្រុមនិងត្រូវជម្រុះរហូត ៣វគ្គ»។

មានសមាជិក ៦នាក់ ដែលក្នុងនោះ៤នាក់ ជានិស្សិតជំនាញវិស្វកម្មជីវសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង២នាក់ជានិស្សិតនៃវិទ្យាស្ថានភាសាបរទេស។ពួកគេបានចំណាយពេលប្រមាណ ៣ខែ ដើម្បីស្រាវជ្រាវ និងសាកល្បងធ្វើសាប៊ូលាងចាននេះ។

ការសម្រេចបង្កើតក្រុមស្រាវជ្រាវ ផលិតសាប៊ូលាងចានស្លឹកគនេះឡើង ដោយសារក្រុមនាងមើលឃើញ ពីអត្ថប្រយោជន៍របស់ស្លឹកគ និងឮការរអ៊ូរទាំរបស់សមាជិកក្រុម ពីកង្វះខាតរបស់សាប៊ូលាងចាន។ មានវ័យ២១ឆ្នាំ កញ្ញាកែម ថា បន្តដូច្នេះ៖ «យើងធ្លាប់យកស្លឹកគមកកក់សក់ ហើយពេលហ្នឹងសមាជិកក្រុមខ្ញុំត្អូញត្អែរនឹងកង្វះខាតរបស់សាប៊ូលាងចាន»។

បច្ចុប្បន្នផលិតសាប៊ូលាងចានច្នៃពីស្លឹកគនេះ មានលក់នៅលើទីផ្សារខ្លះហើយ ហើយក្រុមរបស់នាងមានគម្រោងផលិតសាប៊ូលាងចានបន្ថែមទៀត។ ប៉ុន្តែដំណើរការផលិត ក៏មានផលលំបាកខ្លះដែរ ដោយសារវត្ថុធាតុដើមមិនសូវសម្បូរ។

រៀបចំឡើងជាផ្នែកមួយនៃតាមកំណែទម្រង់ការអភិវឌ្ឍយុវជនរបស់ក្រសួងអប់រំ ស្របទៅតាមការវិវត្តរបស់ពិភពលោក និងតម្រូវការជាក់ស្តែងក្នុងសង្គមកម្ពុជា។ ទន្ទឹមននឹងនេះ ក្រសួងអប់រំ ក៏ចង់លើកកម្ពស់តួនាទីសហគ្រិនវ័យក្មេង នៅកម្ពុជាដែរ។

ជ័យលាភីនៃការប្រកួតនេះ ក៏ជាសញ្ញាបញ្ជាក់ប្រាប់ដល់យុវជនដែលជាសិស្ស និស្សិត ដែលកំពុងតែជ្រើសរើសមហាវិទ្យាល័យដើម្បីសិក្សា។ ការកែច្នៃទាំងនេះ កើតចេញពីការសិក្សាជំនាញបច្ចេកទេស ដែលស្របនឹងទីផ្សារការងារនៅពេលបច្ចុប្បន្ន ដែលកំពុងត្រូវការធនធានមនុស្ស។

ពីមួយឆ្នាំទៅមួយឆ្នាំកំណើននៃការជ្រើសរើសមុខវិជ្ជា វិជ្ជាជីវៈហាក់មានកំណើនតិចតួចបំផុត។ការសិក្សាសព្វថ្ងៃនេះមានពីរសម្រាប់ជ្រើសរើសជាជំនាញមាន ការសិក្សាចំណេះដឹងទូទៅ និងការសិក្សាជំនាញបច្ចេកទេស។ ទីភ្នាក់ងារជាតិមុខរបរ និងការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យដឹងថា ពីមួយឆ្នាំទៅមួយឆ្នាំមាននិស្សិតកម្ពុជា ដែលបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅតែប្រឈមនឹងភាពអត់ការងារធ្វើ។ បញ្ហានេះ បណ្តាលមកពីនិស្សិតភាគច្រើននាំគ្នារៀនតែមុខជំនាញសេដ្ឋកិច្ច និងធុរកិច្ច មិនសូវចាប់អារម្មណ៍រៀនជំនាញបច្ចេកទេសដូចជាមុខជំនាញកសិកម្មសំណង់ និងជាងម៉ាស៊ីនជាដើម។

ក្នុងចំណោមគោលដៅ ១៧ចំណុចរបស់អង្គការសហប្រជាជាតិដែលបានដាក់ជូនរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ឆ្នាំ២០១៦-២០៣០ ខាងមុខ បានជំរុញឲ្យរដ្ឋាភិបាលកម្ពុជា ត្រូវតែលើកកម្ពស់វិស័យកសិកម្មឲ្យមាននិរន្តរភាព តាមរយៈការផ្តល់ជំនាញបច្ចេកទេសដល់ធនធានមនុស្សជំនាន់ក្រោយ ធ្វើយ៉ាងណាឈានទៅបញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែងបញ្ចប់ភាពអត់ឃ្លាន ដើម្បីជានាសម្រេចឲ្យបាននូវសន្តិសុខស្បៀងនៅកម្ពុជា៕

# វិស័យព័ត៌មាន ជាឧបករណ៍ដ៏ចាំបាច់ ដែលត្រូវប្រើប្រាស់បម្រើសង្គមជាតិ



*អត្ថបទ៖ ផល សុផានិត*

រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានថ្លែងថា វិស័យព័ត៌មាន គឺជាឧបករណ៍ដ៏ចាំបាច់ សម្រាប់ការប្រើប្រាស់ នាំមកជាប្រយោជន៍ដល់ការថែរក្សាស្ថិរភាពនយោបាយ ធានាបាននូវឱកាសអភិវឌ្ឍប្រទេសជាតិ។

រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ ក្នុងពិធីអបអរសាទរខួប១០ឆ្នាំ នៃការបង្កើតវិទ្យុជាតិ FM នគរភ្នំ 103 MHz និងខួប៤ឆ្នាំ ថ្ងៃកំណើតទូរទស្សន៍ជាតិខេត្តសៀមរាប កាលពីម្សិលមិញ បាន ថ្លែងសារជាថ្មីម្តងទៀតទៅកាន់បណ្តាស្ថាប័ន អង្គភាពនានា ដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ឡើងវិញទៅលើការរៀបចំតួនាទីអ្នកនាំពាក្យប្រចាំអង្គភាពរបស់ខ្លួន ដើម្បីឆ្លើយតប និងចូលរួមបន្សាបព័ត៌មានមិនពិត ដែលបង្កឲ្យមានបាតុភាពមិនល្អក្នុងសង្គមនោះ។

លោក បានបញ្ជាក់ថា ប្រសិទ្ធភាព នៃការផ្សព្វផ្សាយ គឺស្ថិតនៅលើកិច្ចទំនាក់ទំនងល្អជាមួយស្ថាប័ន នៃប្រភពផ្តល់ព័ត៌មាន ដែលមានការរៀបចំច្បាស់លាស់អ្នកនាំពាក្យ ដែលមានសមត្ថភាព និងជំនឿទុកចិត្ត ក៏ប៉ុន្តែយ៉ាងណាក៏ដោយ អង្គភាពសារព័ត៌មាន មិនអាចខ្វះបាននោះឡើយ គឺការពង្រឹងសាមគ្គីភាពផ្ទៃក្នុងរបស់ខ្លួន។ ដូច្នេះដើម្បីឈានទៅរកគោលដៅនៃការធ្វើឲ្យមានគុណភាព និងប្រសិទ្ធភាព ចាំ បាច់ណាស់ គឺការទំនាក់ទំនងល្អ ជាមួយបណ្តាស្ថាប័ន នៃប្រភពព័ត៌មានទាំងឡាយនោះ ដូចជាមន្ទីរ អង្គភាពជុំវិញខេត្ត និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ផងដែរ។

លោក បានបញ្ជាក់ទៀតថា ក្នុងសម័យកាលប្រើប្រាស់បញ្ញាញាណសិប្បនិម្មិត (បដិវត្ត ៤.០) ព័ត៌មានវាពិតលឿនពេក ច្រើនពេក ហើយក៏ស្មុគ្រស្មាញខ្លាំងណាស់ដែរ ដែលកិច្ចការទាំងនេះ ត្រូវតែរួមកម្លាំងគ្នាធ្វើ ទើបអាចរកឃើញនូវប្រសិទ្ធភាពការងារ ដូច្នេះការជួបប្រជុំប្រមូលព័ត៌មានប្រតិកម្មអវិជ្ជមាន គឺកាន់តែមានសារសំខាន់ថែមទៀត ដើម្បីឆ្លើយតបឲ្យបានទាន់ពេលវេលា។

លោករដ្ឋមន្ត្រីក្រសួងព័ត៌មាន បានថ្លែងទៀតថា ជាទន្និករណ៍គុណប្រយោជន៍របស់អ្នកនាំពាក្យ និងអាចនិយាយបានថាជាបទពិសោធន៍មួយនោះ គឺជោគជ័យ នៃការដឹកនាំប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលត្រូវបានពិភពលោកទទួលស្គាល់។ អ្វីដែលជាកត្តាជោគជ័យនេះ នោះគឺការរៀបចំក្រុមអ្នកនាំពាក្យ ដែលមានសមត្ថភាពគ្រប់គ្រាន់ធ្វើការ២៤ម៉ោង ហើយមជ្ឈដ្ឋាននានានៅជុំវិញ មានទំនុកចិត្ត ។ ក៏ជាបទពិសោធន៍ទទួលបានជោគជ័យផងដែរ គឺការបន្សាបព័ត៌មានបំភិតបំភ័យ ស្តីពីកូវីដ-១៩ ដោយអ្នកនាំពាក្យរបស់ក្រសួងសុខាភិបាល ដែលប្រជាពលរដ្ឋទទួលយកថាជាប្រភពព័ត៌មានផ្លូវការតែមួយគត់ បង្ហាញអំពីស្ថានភាពពិត នៃជំងឺកូវីដ-១៩៕

# កម្ពុជាបង្កើនកម្លាំងទ័ពមួកខៀវមានជំនាញ ដោះមីនដោយប្រើបច្ចេកវិទ្យារ៉ូបូត

*អត្ថបទ៖ ផល សុផានិត*

កាលពីពេលថ្មីៗនេះ មជ្ឈមណ្ឌលជាតិថែរក្សាសន្តិភាព បានបើកវគ្គហ្វឹកហ្វឺនជំនាញប្រើប្រាស់បច្ចេកទេសម៉ាស៊ីនរ៉ូបូតរាវរកគ្រាប់មីនមិនទាន់ផ្ទុះ ជូនកម្លាំងទ័ពមួកខៀវត្រៀមចេញបំពេញបេសកកម្មថែរក្សាសន្តិភាពនៅក្រៅប្រទេស។

បើតាមឧត្តមសេនីយ៍ទោ ប្រាក់ សុទ្ធ អគ្គនាយករងមជ្ឈមណ្ឌលជាតិរក្សាសន្តិភាព ថ្លែងថា កម្លាំងមួកខៀវកម្ពុជា ដែលត្រូវហ្វឹកហ្វឺនបច្ចេកទេសប្រើប្រាស់ម៉ាស៊ីនរ៉ូបូតនេះ ចំនួនជាង ៣០រូប គឺត្រៀមបញ្ជូនចេញបំពេញបេសកកម្មថែរក្សាសន្តិភាពនៅសាធារណរដ្ឋលីបង់ អាហ្វ្រិកកណ្តាល និងប្រទេសម៉ាលី នាពេលខាងមុខ។

ឧត្តមសេនីយ៍ទោ បន្តថា វគ្គហ្វឹកហ្វឺនជំនាញរ៉ូបូតរយៈពេល ១ឆ្នាំនេះ ធ្វើឡើងក្នុងគោលបំណងបង្កើនការយល់ដឹង ក្នុងការប្រើប្រាស់ឧបករណ៍ជំនួយក្នុងការប្រឆាំង និងបន្សាបឧបករណ៍កែច្នៃ និងដោះមីន ដើម្បីបញ្ចៀសហានិភ័យ ខ្ពស់នៅក្នុងតំបន់បេសកកម្ម។

លោកឧត្តមសេនីយ៍ទោបញ្ជាក់ថា កងកម្លាំងមួកខៀវក្រៅពីទទួលបានការហ្វឹកហ្វឺកជំនាញប្រើរ៉ូបូតនេះ កងកម្លាំងទាំងអស់ក៏ត្រូវហ្វឹកហ្វឺនជំនាញវិស្វកម្ម មានសំណង់ផ្តេក និងសំណង់បញ្ឈរ, ជំនាញបោសសំអាតមីន, ជំនាញកម្ទេចយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និង ជំនាញសុខាភិបាល ជំនាញបច្ចេកទេសបើកបររថយន្ត គ្រឿងចក្រ និងជួសជុលកម្រិតស្រាល សព្វាវុធក្បួនយុទ្ធវិធី ឋានលេខា លំហាត់របៀបកងទ័ព ការសិក្សាផ្នែកច្បាប់ជាតិ និងច្បាប់អន្តរជាតិ ច្បាប់សិទ្ធិមនុស្ស ច្បាប់ព្រហ្មទណ្ឌច្បាប់សង្គ្រាម អប់រំចិត្តសាស្ត្រ និងបាញ់គ្រាប់ពិត ជាដើម។

ឧត្តមសេនីយ៍ទោ ប្រាក់ សុទ្ធ បានបន្តថា គ្រប់កងកម្លាំងមួកខៀវដែលត្រៀមខ្លួនដើម្បីចូលរួម បំពេញបេសកកម្មក្រោមឆ័ត្រអង្គការសហប្រជាជាតិនេះ គឺគេសុទ្ធតែទទួលបានការហ្វឹកហ្វឺនពីគ្រូឃោធាចារ្យជំនាញមកពីសហរដ្ឋអាមេរិក ចិន ឥណ្ឌា បារាំងជប៉ុន មន្ត្រី UNMASS របស់អង្គការសហប្រជាជាតិ និងបណ្តាប្រទេសជាមិត្តកម្ពុជាជាច្រើននាក់ទៀត។

សូមបញ្ជាក់ថា ចាប់តាំងពីឆ្នាំ២០០៦មក កម្ពុជាបានបញ្ជូនកម្លាំង ចំនួនសរុប៧១២៣ នាក់ ហើយ ក្នុងនោះ មានស្ត្រីចំនួនជាង ៤១៩នាក់ ទៅចូលរួមបេសកកម្មUN ខណៈបច្ចុប្បន្នកម្ពុជាមានកម្លាំងជិត ១០០០នាក់ ដែលកំពុងបំពេញបេសកកម្មនៅប្រទេសចំនួន ០៤រួមមាន៖ សាធារណរដ្ឋស៊ូដង់ខាងត្បូង អាហ្វ្រិកកណ្តាល លីបង់ និងម៉ាលី៕

# សាលាបច្ចេកទេសដុន បូស្កូ មានវត្តមាន នៅក្នុងប្រទេសកម្ពុជា រយៈពេល៣០ឆ្នាំ



,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,។ រូបភាព៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ

*អត្ថបទ៖ ចេង ជុំនិត្យ*

នៅព្រឹកថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១នេះ សាលាបច្ចេកទេសដុន បូស្កូនៅប្រទេសកម្ពុជា បានប្រារព្ធកម្មវិធីបើកខួបនៃ «វត្តមានដុនបូស្កូ ៣០ឆ្នាំ» នៅប្រទេសកម្ពុជា។

កម្មវិធីនេះបានប្រព្រឹត្តិឡើងតាមរយៈវីដេអូ Conference ក្រោមអធិបតីភាពលោកបូជាចារ្យ រ៉ូអែល សូតូ ដែលជាអធិការមូលនិធិដុន បូស្កូកម្ពុជា នៅសាលាបច្ចេកទេសដុន បូស្កូភ្នំពេញ។

ថ្លែងនៅក្នុងធម្មទេសនាបើកកម្មវិធី លោកបូជាចារ្យ រ៉ូអែល សូតូ បានមានប្រសាសន៍ថា៖ «លោកឪពុកយ៉ូហាន បូស្កូ កើតមកជាកូនកសិករក្រីក្រ ដែលកើតមកដើម្បីជួយដល់យុវជនក្រីក្រ»។

លោកបានបន្តថា លោកយ៉ូហាន បូស្កូ ជាកូនកំព្រាឪពុកតាំងពីកុមារភាព ដោយទុកឱ្យលោករស់នៅជាមួយម្តាយជាស្ត្រីមេម៉ាយ និងបងប្រុសរបស់លោកម្នាក់។ បន្ទាប់ពីលោកយ៉ូហាន បូស្កូ ទទួលអគ្គសញ្ញាជាបូជាចារ្យ លោកបានបំពេញបេសកកម្មជួយដល់យុវជនក្រីក្រ ដែលគេបោះបង់ចោល។

លោកអធិការដដែលរូបនេះបានបន្តទៀតថា យុវជនដែលសង្គមបោះបង់ចោល លោកបូជាចារ្យបូស្កូបានផ្តល់ឱ្យនូវកន្លែងស្នាក់នៅ ព្រមទាំងអាហារ និងជំនាញដើម្បីឱ្យពួកគេអាចយកទៅធ្វើការដើម្បីប្រកបរបរចិញ្ចឹមជីវិត។

តាមរយៈលោកបូស្កូ យុវជនរាប់លាននាក់នៅជុំវិញពិភពលោក បានផ្លាស់ប្តូរវាសនា ក្នុងនោះក៏មានយុវជននៅក្នុងប្រទេសកម្ពុជាផងដែរ។

កម្មវិធីនេះមានការចូលរួមពីសាលាដុន បូស្កូផ្នែកបុរសខេត្តកែប ខេត្តព្រះសីហនុ ខេត្តបាត់ដំបងក្រុងប៉ោយប៉ែត និងសាលាបច្ចេកទេសដុន បូស្កូភ្នំពេញ។ កម្មវិធីនេះប្រារព្ធឡើងដើម្បីរំលឹកពីវត្តមាន ៣០ ឆ្នាំរបស់មូលនិធិ ដុនបូស្កូនៅក្នុងប្រទេសកម្ពុជា។

គួរបញ្ជាក់ផងដែរថា តាំងពីឆ្នាំ១៩៨៨មូលនិធិដុន បូស្កូ មានសកម្មភាពជួយបង្រៀនវិជ្ជាជីវៈដល់យុវជនយុវនារីខ្មែរនៅក្នុងជំរុំជនភៀសខ្លួននៅតាមបន្ទាត់ព្រំដែនខ្មែរ-ថៃ។ ពេលនោះមូលនិធិនេះ ចូលមកកម្ពុជាក្រោយការស្នើសុំរបស់អង្គការសហប្រជាជាតិ។

មូលនិធិដុន បូស្កូបានចូលមកដល់ប្រទេសកម្ពុជា ជាផ្លូវការក្នុងឆ្នាំ១៩៩១។ តាមរយៈមូលនិធិនេះ សាលាបច្ចេកទេសដុន បូស្កូបានបង្កើតឡើងសំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាជំនាញអគ្គិសនី មេកានិច អេឡេចត្រូនិក គ្រឿងម៉ាស៊ីន រោងពុម្ព ជំនាញបំរើការនៅតាមសណ្ឋាគារ និងទេសចរណ៍ ជំនាញកាត់ដេរ លេខាធិការនិងគណនេយ្យ និងជំនាញផ្នែកទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយជាដើម។

លោកគ្រូទ្រី សីហា ជំនួយការមូលនិធិដុន បូស្កូកម្ពុជា បានអោយដឹងថា ក្នុងរយៈពេល ៣០ ឆ្នាំមកនេះដុន បូស្កូបានរីកលូតលាស់បានរហូតដល់ ៥ សាខានៅជុំវិញប្រទេសកម្ពុជា និងបានផ្ទេរជំនាញទៅដល់យុវជនកម្ពុជា បានជិត ២០០០០ នាក់។ ដោយអតីតសិស្សចេញពី ដុនបូស្កូភាគច្រើនទទួលបានការងារល្អ និងមួយចំនួនទៀតបានយកជំនាញទៅបើកអាជីវកម្មផ្ទាល់ខ្លួនទៀតផង។ ពិសេសជាងនេះទៅទៀត ដុន បូស្កូតែងទទួលបានការឆ្លើយតបពី ក្រុមហ៊ុន សហគ្រិនផ្សេងៗថា សិស្សពីដុន បូស្កូភាគច្រើនតស៊ូក្នុងការងារ និងមានសីលធម៌ល្អ ស្មោះត្រង់និងព្យាយាមធ្វើការ។

លោកបានបន្តទៀតថា មូលនិធិដុន បូស្កូមិនត្រឹមតែមានបណ្តុះបណ្តាលវិជ្ជាជីវៈប៉ុណ្ណោះទេ ដុនបូស្កូក៏មានមូលនិធិសំរាប់កុមារផងដែរ ដោយក្នុងឆ្នាំនេះ មូលនិធិកំពុងផ្តល់ជំនួយដល់កុមារ ជាង ១០០០ នាក់នៅទូទាំងប្រទេស ដោយជំនួយអង្គការនេះ ផ្តល់អោយកុមារតាំងពីតូចរហូតបានរៀនចប់ថ្នាក់ទី ១២ ៕





,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,, ,,,,,។ រូបភាព៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ





*បេក្ខជន២៥នាក់បានទទួលអគ្គសញ្ញាលាបថ្វាសក្លាយជាកាតូលិកពេញវ័យខាងជំនឿ ក្រោមអធិបតីភាពលោក អូលីវីយេ ផ្មឹតហាស្លេរ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច។ **រូបភាព៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ***

# បេក្ខជន២៥នាក់ទទួលអគ្គសញ្ញាលាបថ្វាសនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច

*អត្ថបទ៖ ដាលីស*

បេក្ខជន២៥នាក់នៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង បានទទួលអគ្គសញ្ញាលាបថ្វាសក្រោមអធិបតីភាពលោក អូលីវីយេ ផ្មឹតហាស្លេរ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដោយមានគ្រីស្តបរិស័ទជាច្រើននាក់បានចូលរួមយ៉ាងច្រើនកុះករ។

កម្មវិធីនេះប្រារព្ធឡើងនៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច នាថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១ កន្លងមកនេះ។

ក្នុងពិធីនោះ លោកអភិបាលបានហៅបេក្ខជនចំឈ្មោះម្នាក់ម្តងៗ មកផ្តល់អគ្គសញ្ញាលាបថ្វាសដោយយកប្រេងគ្រីស្មា គូសជាសញ្ញាឈើឆ្កាងថ្ងាសបេក្ខជន។ លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ណែនាំដល់បេក្ខជនទាំង២៥នាក់នេះថា នេះជាពេលវេលាមួយដើម្បីឱ្យយើងពិចារណាអំពីភារកិច្ច អំពីតួនាទីរបស់យើងជាគ្រីស្តបរិស័ទនៅក្នុងសង្គមបច្ចុប្បន្ននេះ ដោយយកគំរូតាមលោកប៉ូល។

លោកអូលីវីយេ បានមានប្រសាសន៍ថា៖ «គោលដៅរបស់យើងភ្ជាប់ជាមួយព្រះជាម្ចាស់ ស្គាល់សិរីរុងរឿងរបស់ព្រះជាម្ចាស់»។ លោកអូលីវីយេ បញ្ជាក់ទៀតថា ព្រះវិញ្ញាណដ៏វិសុទ្ធជាសេចក្តីស្រឡាញ់ហូរចេញពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណដ៏វិសុទ្ធជាសេចក្តីក្លាហាន ជាកម្លាំងកាយកម្លាំងចិត្ត ជាព្រះជាម្ចាស់ផ្ទាល់ដែលប្រទានព្រះប្រាជ្ញាញាណឱ្យបងប្អូន និងឱ្យយើងទាំងអស់គ្នា ដើម្បីបំពេញភារកិច្ចរបស់យើងដូចសន្តប៉ូលបានប្រកាសដំណឹងល្អ។

លោកអភិបាលភូមិភាគភ្នំពេញ ក៏បានស្នើដល់គ្រីស្តបរិស័ទទាំងអស់ពិចារណា ធ្វើដូចម្តេចដើម្បីអនុវត្តន៍ដូចលោកប៉ូល គឺភារកិច្ចនៃការប្រកាសដំណឹងល្អ? តើធ្វើដូចម្តេចដើម្បីចូលរួមជាមួយព្រះយេស៊ូពេញមួយថ្ងៃ?

លោកអភិបាលអូលីវីយេ បន្ថែមដោយរំឭកដល់គ្រីស្តបរិស័ទទាំងអស់អំពីលក្ខណៈនិងអត្តសញ្ញាណរបស់គ្រីស្តបរិស័ទដែលជាព្រះបន្ទូលផ្តាំផ្ញើរបស់ព្រះយេស៊ូគឺ «សូមស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ»។

លោកបន្តទៀតថា អត្តសញ្ញាពិសេសមួយទៀតគឺយើងមានសមត្ថភាពលើកលែងទោសឱ្យគ្នាទៅវិញទៅមកដោយពឹងផ្អែកលើព្រះជាម្ចាស់ក្នុងនាមជាបុត្រធីតារបស់ព្រះជាម្ចាស់។ លោកអូលីវីយេបានបន្ថែមថា៖ «សម្រាប់យើងជាគ្រីស្តបរិស័ទ យើងត្រូវតែជាទូតនៃសេចក្តីសុចរិត ជាទូតនៃភាពយុត្តិធម៌ ដោយធ្វើជាគំរូដោយប្រឆាំងនូវភាពអយុត្តិធម៌»។

បេក្ខជន គៀន តារា ជាអ្នកបម្រើអាសនៈនៅព្រះវិហារសន្តយ៉ូសសែប ផ្សារតូច បានឱ្យដឹងថា លោកសប្បាយចិត្តដោយបានទទួលអគ្គសញ្ញាលាបថ្វាស ក្រោយពីបានទទួលការអប់រំពីព្រះសហគមន៍រយៈពេលជាយូរឆ្នាំមកនេះ។

តារាបន្តថា៖ «អគ្គសញ្ញានេះ បានធ្វើឱ្យខ្ញុំក្លាយជាកាតូលិកពេញវ័យខាងជំនឿ និងក្រោយពីស្តាប់ធម្មទេសនារបស់លោកអភិបាលដែលបានផ្តែផ្តាំឱ្យពួកខ្ញុំទៅប្រកាសដំណឹងល្អ។ ខ្ញុំយល់ថា ក្នុងនាមយើងជាកាតូលិកយើងត្រូវប្រកាសដំណឹងល្អដល់អ្នកជិតខ្លួនយើង និងអ្នកដែលមិនដែលស្គាល់ព្រះសហគមន៍ ដើម្បីឱ្យគេដឹងពីសាសនាកាតូលិក»។

យុវជនតារាបញ្ជាក់បន្ថែមថា ក្រោយពេលទទួលអគ្គសញ្ញានេះ លោកនឹងទៅប្រកាសដំណឹងល្អដោយនិយាយប្រាប់មិត្តភក្តិនៅសាលាអំពីព្រះសហគមន៍ និងចូលរួមជាមួយក្រុមយុវជន និងបន្តជាមួយក្រុមបម្រើអាសនៈ ដើម្បីបង្ហាញសកម្មភាពប្រកាសដំណឹងល្អនេះ៕

# កុមារកាន់តែច្រើន កង្វះខាតថ្នាក់រៀននិងគ្រូកើតមាន



*អត្ថបទ៖ កែវ កញ្ញា*

សាលាឡាសាលពោធិ៍ធំ ក្នុងឆ្នាំសិក្សា២០២០-២០២១នេះមានចំនួនកូនសិស្សកើនឡើងជិត១០០ភាគរយធ្វើឲ្យសាលានេះខ្វះខាតបន្ទប់សិក្សា និងគ្រូបង្រៀន។

តាមរយៈព្រឹត្តិប័ត្ររបស់ក្រុមគ្រួសារបងប្រុសឡាសាល ជាអ្នកបង្កើតសាលាឡាសាលពោធិ៍ធំបានឲ្យដឹងថា ក្នុងឆ្នាំសិក្សាចាស់ មានសិស្សត្រឹមតែ២២០នាក់ប៉ុណ្ណោះ ដែលក្នុងនោះមានថ្នាក់មត្តេយ្យចំនួន៤ និងថ្នាក់បឋមសិក្សាចំនួន៤ ប៉ុន្តែបច្ចុប្បន្នក្នុងឆ្នាំសិក្សា២០២០-២០២១នេះ ចំនួនកូនសិស្សបានកើនឡើងដល់៤០០នាក់។

ប្រភពដដែលបានឲ្យដឹងទៀតថា បេសកកម្មរបស់សាលានេះ គឺផ្តល់ការអប់រំដល់កុមារក្រីក្រដោយឥតបង់ប្រាក់ និងមានអាហារដល់ពួកគេផងដែរ។

កម្មវិធីសិក្សារបស់សាលានេះ គឺគោរពតាមគោលការណ៍អប់រំណែនាំរបស់ក្រសួងអប់រំយុវជននិងកីឡា ដោយរួមបញ្ចូលភាសាបរទេស កីឡា និងបំណិនជីវិត។

បច្ចុប្បន្នសាលាឡាសាលពោធិ៍ធំ ដែលជាសាលារបស់ព្រះសហគមន៍កាតូលិកនេះ មានគ្រូជនជាតិខ្មែរចំនួន១៥នាក់ បងប្រុសឡាសាលចំនួន៣នាក់ និងបងស្រី ឡាសាលចំនួន៣នាក់ដែលមានបងប្រុសយ៉ូសែប ង្វៀន ឌឹអាញ ជានាយកសាលា។

ក្នុងអំឡុងពេល មានវិបត្តិកូវីដ១៩ សាលាឡាសាលពោធិ៍ធំ បានចែករំលែកនូវគ្រឿងឧបភោគបរិភោគដល់គ្រួសារសិស្សក្រីក្រចំនួន២លើក ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត និងបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដែលមួយលើកៗមានចំនួន១០០គ្រួសារទទួលបានអង្ករ និងមី៕

# មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជាបើកឆ្នាំសិក្សាថ្មី

*អត្ថបទ៖ដាលីស*

មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា បានបើកឆ្នាំសិក្សាថ្មីក្នុងឆ្នាំ ២០២០-២០២១ នាល្ងាចថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១នេះ នៅមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា ក្នុងសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

កម្មវិធីនេះធ្វើឡើងក្រោមអធិបតីភាពលោក អូលីវីយេ ផ្លឹសហស្សេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ព្រមទាំងមានមាតាបិតា និងអាណាព្យាបាលនិស្សិតឆ្នាំទីមួយចូលរួមជាច្រើនកុះករ។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ពីរកឱ្យយកចិត្តទុកដាក់ ក្នុងការអនុវត្តតាមការវិធានការប្រតិបត្តិការស្តង់ដារអនាម័យរបស់ក្រសួងសុខាភិបាល។ លោកក៏បានលើកទឹកចិត្តដល់ឪពុកម្តាយរបស់និស្សិតថា កុំឱ្យមានការព្រួយបារម្ភចំពោះកូនដែលបានចេញពីផ្ទះមកបន្តការសិក្សានៅទីក្រុងភ្នំពេញ និងស្នាក់នៅក្នុងមណ្ឌលនិស្សិតនេះ។

លោកអភិបាលបានថ្លែងថា ៖ «មណ្ឌលនិស្សិត ជាមណ្ឌលមួយដែលយកចិត្តទុកដាក់អប់រំនិស្សិតឱ្យទៅជាមនុស្សពេញលក្ខណៈ គឺចេះរស់នៅក្នុងសង្គមយ៉ាងត្រឹមត្រូវ ចេះគោរពគ្នាទៅវិញទៅមក ចេះបង្កើតទំនាក់ទំនងជាមួយអ្នកដទៃ ក៏ដូចជាជាមួយព្រះជាម្ចាស់ដែរ ហើយថែរក្សាជីវិតដែលព្រះជាម្ចាស់ប្រទានឱ្យយើង»។

លោកអូលីវីយេសង្ឃឹមថាឆ្នាំនេះ និស្សិតទាំងអស់ចេះរស់នៅជាមនុស្សដែលចេះបត់បែន និងយកចិត្តទុកដាក់រៀន ទោះបីតាមបណ្តាញសង្គមក៏ដោយ។

លោកប៊ុន សុបិន្ត ជំនួយការសម្របសម្រួលមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា បានលើកឡើងផងដែរថា ឆ្នាំនេះមណ្ឌលបើកឆ្នាំសិក្សាយឺត ដោយសារបញ្ហានៃការរីករាលដាលនៃជំងឺកូវីដ១៩។

លោកបានប្រាប់ឱ្យដឹងថា៖«អ្វីដែលជាគោលការណ៍របស់មណ្ឌលនិស្សិតបើកឆ្នាំសិក្សា គឺ ដើម្បីឱ្យអាណាព្យាបាលឆ្នាំទីមួយបានស្គាល់ពីមណ្ឌល ដែលជាកន្លែងកូនៗរបស់គាត់មករស់នៅ»។

លោកប៊ុន សុបិន្តបានបញ្ជាក់បន្ថែមថា ឆ្នាំនេះមណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជាទទួលនិស្សិតជំនាន់ទី២៣ចំនួន១៧នាក់ មកពីតាមបណ្តាខេត្តមួយចំនួននៅក្នុងប្រទេសកម្ពុជាតាមរយៈព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ។

ជំនួយការរូបនេះបានបន្តថា មណ្ឌលនិស្សិតមាន៤ចំណុចដើម្បីជួយដល់និស្សិតក្នុងការទទួលការសិក្សាដោយជោគជ័យគឺ ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគាត់ម្នាក់ៗ, ការអភិវឌ្ឍខ្លួនទៅតាមទេពកោសល្យនិងអំណោយទានធម្មជាតិ, ជីវិតរួម គឺរស់នៅជាក្រុមដោយចេះសម្រប សម្រួល តាមចំពោះគ្នាទៅវិញទៅមកដើម្បីត្រៀមខ្លួនធ្វើការនៅក្នុងសង្គម។

លោកបន្តថា ចំណុចចុងក្រោយគឺការរីកចម្រើនផ្លូវវិញ្ញាណរបស់និស្សិតម្នាក់ៗ ដោយនិស្សិតជាកាតូលិកត្រូវចូលរួមកម្មវិធីអភិបូជានិងអានអត្ថបទព្រះគម្ពីរ រីឯនិស្សិតដែលជាពុទ្ធសាសនិកយើងមានកម្មវិធីសមាធិរៀងរាល់ល្ងាចថ្ងៃសុក្រផងដែរ។

មណ្ឌលនិស្សិតព្រះសហគមន៍កាតូលិកកម្ពុជា បានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ និងបានជួយដល់និស្សិតក្រីក្រដែលមកពីជនបទ្រះខេត្តក្រុងក្នុងប្រទេសកម្ពុជា ឱ្យរៀននៅក្នុងសាកលវិទ្យាល័យនានាក្នុងទីក្រុងភ្នំពេញសរុប៣៧៤នាក់ និងបានបញ្ចប់ការសិក្សាដោយជោគជ័យចំនួន៣៥៧នាក់។ បច្ចុប្បន្ន មណ្ឌលនេះមាននិស្សិតកំពុងស្នាក់នៅចំនួន៦៤នាក់ ក្នុងនោះមាននិស្សិតស្រីចំនួន៣៤នាក់ ហើយនិស្សិតឆ្នាំទីមួយមានចំនួន១៧នាក់ផងដែរ៕




# ជំនួបយុវជនកាតូលិកមណ្ឌលសកម្មភាពភ្នំពេញខាងជើង

*អត្ថបទ៖ ដាលីស*

យុវជនដែលមានអាយុចន្លោះ១៣ដល់១៨ឆ្នាំ នៅតាមបណ្តាព្រះសហគមន៍ ទាំង៩នៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង ចំនួន៥០នាក់ ជួបជុំគ្នានាល្ងាច ថ្ងៃទី២៩ ដល់ថ្ងៃទី៣១ មករា ២០២១ ដើម្បីរិះគិតរួមគ្នាក្រោមប្រធានបទ "ចេញទៅប្រកាសដំណឹងល្អ" នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច និងដឹកនាំដោយលោកបូជាចារ្យ ផ្រមផុង ស៊ីហារ៉ាត់ (ប៊ីត)។

យុវជន ហួត ម៉េងធួ ជាប្រធានយុវជន បានឱ្យដឹងថា សិក្ខាសាលានេះរៀបចំឡើងដើម្បី ជួយដល់យុវជននៅក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង ទាំងអស់ឱ្យមានសកម្មភាពរួមគ្នា និងបានស្គាល់គ្នាទៅវិញទៅមក ហើយក៏ជាមធ្យោបាយមួយដើម្បីបង្រៀនពួកគាត់ឱ្យចេះសាមគ្គីគ្នាដែរ។

ប្រធានយុវជនបន្តថា យុវជនគឺជាស្នូលនៃព្រះសហគមន៍ ដូច្នេះពួកគេត្រូវដឹងពីតួនាទី និងមានសកម្មភាពអ្វីខ្លះ ដើម្បីចេញទៅប្រកាសដំណឹងល្អ នៅក្នុងជីវិតប្រចាំថ្ងៃ នៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គម ដោយបង្កើតសកម្មភាពនានានៅក្នុងព្រះសហគមន៍ផ្ទាល់ខ្លួនរបស់ពួកគេ ក៏ដូចជា ការប្រកាសដំណឹងល្អតាមរយៈបណ្តាញសង្គមផងដែរ។

លោកបូជាចារ្យ ប៊ីត បានមានប្រសាសន៍ ទៅកាន់យុវជនទាំងអស់ថា៖ «ប្រសិនបើយើងមានចិត្តចង្អៀត ចិត្តច្រណែន តើយើងទៅប្រកាសអ្វី? លោកបន្តថា ការប្រកាសដំណឹងល្អគឺចេញពីខ្លួនយើងផ្ទាល់ ដោយចាប់ផ្តើមធ្វើជាគំរូដល់គេ និងបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ឱ្យគេឃើញ»។

លោករំឭកអំពីអត្ថបទព្រះគម្ពីរថា ហេតុអ្វីបានជាខ្មោចស្គាល់ព្រះយេស៊ូ? រីឯយើងទាំងអស់គ្នានៅទីនេះវិញ តើយើងស្គាល់ព្រះយេស៊ូឬអត់? លោកថា ប្រសិនបើយើងស្គាល់ព្រះយេស៊ូ នោះយើងនឹងប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយមានចិត្តស្រឡាញ់ និងចិត្តមេត្តាករុណាអាណិតអាសូរ។

ក្រៅពីការណែនាំ អំពីរបៀបនៃការប្រកាសដំណឹងល្អ លោកបូជាចារ្យ ក៏បានដាស់តឿនយុវជនឱ្យយល់ពីតម្លៃរបស់ខ្លួន ក៏ដូចជាការរស់នៅប្រចាំថ្ងៃ ជាពិសេសលោកក៏បានបង្ហាញផងដែរនូវអ្វីដែលមនុស្សយើងមិនអាចយកលុយទៅទិញបាន ដើម្បីជួយដល់យុវជនក្នុងការប្រើប្រាស់ជីវិតឱ្យបានពេញលេញ ដូចជា ខ្យល់ដង្ហើម ឱកាស និងពេលវេលា។

យុវនារី សុខ ចន្ថា មកពីព្រះសហគមន៍ ពោធិ៍ធំ បានឱ្យដឹងថា រយៈពេលសិក្សាប៉ុន្មានថ្ងៃនេះ ខ្ញុំបានទទួលចំណេះដឹងជាច្រើនអំពីរបៀបនៃការប្រកាសដំណឹងល្អ តាមវិធីសាស្ត្រផ្សេងៗ ដូចជាការប្រកាសដំណឹងល្អទៅគ្រួសារ មិត្តភក្តិ ឬអ្នកជិតខាងយើងតាមវិធីងាយៗ ដោយមិនចាំបាច់ដូចព្រះយេស៊ូពេក គឺគ្រាន់តែសកម្មភាពអធិដ្ឋានមុនញ៉ាំបាយក៏អាចប្រកាសដំណឹងល្អបានដែរ។

ការប្រកាសដំណឹងល្អនេះ ជាតួនាទីរបស់ខ្ញុំជាគ្រីស្តបរិស័ទ និងជួយឱ្យខ្ញុំកាន់តែមានជំនឿរឹងមាំបន្ថែមទៀត។ នេះជាជំនួបដំបូងរបស់ក្រុមយុវជនរបស់ មណ្ឌលសកម្មភាពភ្នំពេញខាងជើង មកពី៩ព្រះសហគមន៍ដូចជា ផ្សារតូច អរិយក្សត្រ ពោធិ៍ធំ ក្តីកណ្តាល មាត់ក្រសាស់ ព្រែកតាទែន សែនសុខ ស្វាយប៉ាក និងកំពង់ហ្លួង។

កាលពីឆ្នាំ២០២០ ក្រុមយុវជនគ្រោងនឹងមានជំនួបផ្ទាល់បែបនេះ ប៉ុន្តែត្រូវបានខកខានដោយបញ្ហាកូវីដ១៩ ហេតុនេះក្រុមយុវជនក៏បាន បង្កើតកម្មវិធីដើម្បីជួបជុំ និងមានទំនាក់ទំនងរវាងគ្នានិងតាមរយៈបណ្តាញសង្គម ដោយការបង្កើតផេកក្រុមយុវជនមណ្ឌលសកម្មភាពភ្នំពេញខាងជើង និងមាន ការផ្សាយផ្ទាល់ នូវកម្មវិធីកម្សាន្ត សំណួរនិងចម្លើយជាមួយយុវជនផងដែរ៕



# CCHS បានផ្តល់សេវាសុខភាពដល់អ្នកជំងឺចំនួន ១៩៩៨នាក់និងបានពិគ្រោះជំងឺជាង៥៤០០ដង ក្នុងឆ្នាំ២០២០




*សកម្មភាពបុគ្គលិកបម្រើការក្នុងសេវាថែទាំសុខភាពព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ (CCHS) ពិនិត្យសុខភាព និងផ្តល់ថ្នាំជូនដល់អ្នកជំងឺ។ **រូបភាព៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ***

*អត្ថបទ៖ វេជ្ជ. ជួង សារឿន*

យោងតាមរបាយការណ៍របស់សេវាសុខភាពព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ (CCHS) ចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២០ បានផ្តល់សេវាសុខភាពជូនដល់អ្នកជំងឺសរុបចំនួន១,៩៩៨នាក់។ ក្នុងចំណោមអ្នកទាំងនោះ CCHS បានធ្វើការពិគ្រោះជំងឺបានចំនួន៥៤១៩ ដង។

កាលពីថ្ងៃទី៥ ខែកុម្ភៈឆ្នាំ ២០២១ នៅព្រះសហគមន៍សន្តប៉ូល និងសន្ត សិលា ភ្នំពេញថ្មី បានធ្វើការប្រជុំនិងបង្ហាញរបាយការណ៍របស់សេវាសុខភាពព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ (CCHS) ក្រោមការណែនាំដោយលោកអភិបាល អូលីវីយេ ឆ្មីតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

របាយការណ៍ដដែលបានបង្ហាញថា អ្នកជំងឺទាំងអស់នេះមកពីគ្រប់មណ្ឌលថែទាំអ្នកជំងឺនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្នុងនោះមាន៣៦% ជាអ្នកជំងឺបុរស និង៦៤% ជាស្ត្រី។ ក្នុងចំណោមអ្នកជំងឺ៩១១ នាក់ (៤៥%) មកពីក្នុងកម្មវិធីតាមខេត្ត និង៥១១នាក់ (២៨%) នៅមណ្ឌលថែទាំត្រចៀក សន្ត បឺន័រ និង៥៣៦នាក់ (២៧%) នៅមណ្ឌលសន្ត លូកា និងនិងសន្តី អេលីហ្សាបែត។

មានប្រសាសន៍ទៅកាន់បុគ្គលិកបម្រើការក្នុងសេវាសុខភាពចំនួន២២នាក់លោកអភិបាល អូលីវីយេ បានរំលឹកឡើងវិញនូវពាក្យជូនពរចំនួន ៥ ចំនុចក្នុងឱកាសបុណ្យព្រះគ្រីស្តសម្តែងព្រះអង្គគឺ «សូមទទួលព្រះពរពីព្រះជាម្ចាស់ដ៏ពេញលក្ខណៈ ជាពរដែលសាកសិទ្ធបំផុត និងជាពិសេសសំរាប់អ្នកមានបន្ទុកព្យាបាលអ្នកជំងឺ ក្រោយពេលដែលយើងទទួលព្រះពរនេះហើយ យើងអាចផ្ទេរទៅដល់អ្នកជំងឺបាន»។

ចំណុចទី២ លោកអភិបាលក៏បានរំលឹកដល់អ្នកផ្តល់សេវាទាំងអស់ថា ដោយទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំជីវិតទាំងអស់ ព្រោះក្នុងព្រះបន្ទូល ព្រះយេស៊ូបានធ្វើការយកចិត្តទុកដាក់ ថែរក្សា និងព្យាបាលចំពោះអ្នកជំងឺ។

មួយទៀត លោកអភិបាលក៏បានទទូចឲ្យបង្ហាញពីអត្តសញ្ញាណជាគ្រីស្តបរិស័ទកាតូលិកខ្មែរ ព្រោះថា នេះជាសញ្ញាសំគាល់ដល់បងប្អូនខ្មែរ។ ពេលស្វាគមន៍អ្នកជំងឺ គឺចាំបាច់ត្រូវបង្ហាញពីការយកចិត្តទុកដាក់ បង្ហាញថា យើងបានទទួលនូវការត្រាស់ហៅមួយយ៉ាងពិសេសសំរាប់បម្រើដល់អ្នកជំងឺ គឺបម្រើដោយក្តីស្រលាញ់។ ដោយដឹងថាក្នុងនាមយើងជាគ្រីស្តបរិស័ទយើងទទួលបានកំលាំងពិសេសពីព្រះជាម្ចាស់ជានិច្ច។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា ៖ «ចំពោះគ្រីស្តបរិស័ទ ត្រូវពង្រឹងជំនឿរបស់យើងឲ្យបានរឹងមាំ ព្រោះថាជំនឿរបស់យើងជាសេចក្តីសង្ឃឹមមួយដែលនាំឲ្យយើងបន្តដំណើរទៅមុខបាន ក្នុងការថែទាំជូនដល់អ្នកជំងឺ»។

ជាងនេះទៅទៀតលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញបានបញ្ជាក់ឲ្យយកចិត្តទុកដាក់ដើម្បីសំដែងធម៌មេត្តា ករុណា ទោះបីធ្វើការក្នុងឋានៈណាក៏ដោយ គឺត្រូវទទួលស្គាល់ថា កាលណាយើងទទួលអ្នកជំងឺណាម្នាក់ គឺគេបានចូលទៅក្នុងជីវិតរបស់យើង និងជាក្រុមគ្រួសាររបស់យើង។

ក្រៅពីពរទាំង៥ប្រការនេះ លោកអភិបាល អូលីវីយេ បានដាក់ជាសំណួររិះគិតអំពីបទពិសោធន៍ការងារអំឡុងពេលកូវីដ១៩ ក្នុងឆ្នាំ២០២០ តើអ្វីដែលចំនុចខ្លាំងនិងខ្សោយរបស់CCHS និងតើCCHSអាចធ្វើអ្វីខ្លះដើម្បី រីកចំរើនក្នុងការងារក្នុងឆ្នាំ ២០២១ នេះ?

លោកអភិបាល បានក្រើនរំលឹកផងដែរ ថា តើCCHS ធ្វើយ៉ាងណាដើម្បីកាត់បន្ថយអត្រាឈឺរបស់ប្រជាជន? តាមរយៈការអប់រំ ទៅដល់យុវជន និងបងប្អូននៅតាមភូមិជាដើម។

លោកអភិបាល អូលីវីយេ បានធ្វើការណែនាំដល់ កម្មវិធីសុខភាពព្រះសហគមន៍ ដើម្បីបង្កើតនូវវប្បធម៌ នៃការយកចិត្តទុកដាក់ក្នុងការថែទាំដល់អ្នកជំងឺ ដោយចេះអង្គុយលេងជាមួយអ្នកជំងឺ ស្តាប់ បង្កើតទំនាក់ទំនងផ្ទាល់ខ្លួន យល់ចិត្តគ្នា ដោយមានចិត្តអាណិតមេត្តា និងយល់អំពីការឈឺចាប់របស់គេ។

CCHS បានបង្កើតឡើងដើម្បីបំពេញបេសកកម្ម បង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ តាមរយៈការបម្រើអ្នកជំងឺ និងបង្រៀនបងប្អូនអប់រំពីការថែទាំសុខភាព។ ជាមួយគ្នានេះផងដែរ ការបម្រើ និងថែទាំ លើកទឹកចិត្តជូនដល់អ្នកជំងឺមហារីក ជាផ្នែកមួយដ៏ពិសេសនៃសេវាកម្មទាំងមូលរបស់ CCHS។

ក្នុងឆ្នាំ២០២០កន្លងមកនេះ មានអ្នកជំងឺមហារីកចំនួន ៣៤នាក់ ត្រូវបានថែទាំ ដោយធ្វើការបំបាត់ការឈឺចាប់ដល់ពួកគេ។

រយៈពេល ៤ ឆ្នាំកន្លងមកនេះ CCHS បានចុះហត្ថលេខាលើពិធីសារនៃកិច្ចសហការជាមួយ អង្គការបំបាត់ការឈឺចាប់គ្មានព្រំដែន (DSF) ធ្វើការលើការថែទាំសម្រន់ដល់អ្នកជំងឺមហារីកនៅមណ្ឌលសន្តី អេលីហ្សាបែត និងការថែទាំតាមផ្ទះ។

អង្គការបំបាត់ការឈឺចាប់គ្មានព្រំដែន (DSF) ជាអ្នកទទួលខុសត្រូវលើការផ្តល់ថ្នាំសម្រាប់បំបាត់ការឈឺចាប់។ ចំណែកឯ CCHS ផ្តល់នូវធនធានមនុស្សនិងទីកន្លែងសម្រាប់ថែទាំ និងផ្តល់ការថែទាំដល់ផ្ទះចំពោះអ្នកដែលមិនអាចផ្លាស់ទីមកភ្នំពេញ។ ក្នុងឆ្នាំ២០២០ នេះមានអ្នកជំងឺមហារីកចំនួន ១១ នាក់ដែលបានស្លាប់ដោយស្ងប់ចិត្ត និងយល់ដឹងអំពីបញ្ហារបស់គាត់ និងមិនមានការឈឺចាប់៕



*លោកអភិបាល អូលីវីយេ ថ្លែងទៅកាន់បុគ្គលិកបម្រើការក្នុងសេវាសុខភាពនៅព្រះសហគមន៍សន្តប៉ូល និងសន្តសិលា ភ្នំពេញថ្មី។ **រូបភាព៖ ព្រះសហគមន៍ភូមិភាគភ្នំពេញ***

# សម្ព័ន្ធអង្គការកាតូលិកដើម្បីមេត្តាករុណានិងការអភិវឌ្ឍ រិះគិតអំពីសកម្មភាពឆ្នាំ២០២១

*អត្ថបទ៖ ដាលីស*

សម្ព័ន្ធអង្គការកាតូលិកដើម្បីមេត្តាករុណានិងការអភិវឌ្ឍ (CACD) ដឹកនាំដោយអភិបាលភូមិភាគភ្នំពេញ លោក អូលីវីយ៉េ ឆ្មីតហាស្លេរ បានរិះគិតរួមគ្នាអំពីរបៀបយកចិត្តទុកដាក់ក្នុងការកសាងសន្តិភាព ដោយមានការណែនាំពីសារលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្ស។

កម្មវិធីនេះ ប្រព្រឹត្តទៅកាលពីខែមករា នៅអង្គការការីតាសកម្ពុជា ក្នុងសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ដោយមានអ្នកចូលរួមចំនួន៤០រូប។

លោក គឹម រតនា តំណាងគណៈកម្មការនៃ CACD និងជានាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជាបានថ្លែងស្វាគមន៍និងស្នើឱ្យមានការសហការរួមគ្នាបន្តទៀតដោយរិះគិតពីយន្តការដើម្បីរួមគ្នាគឺធ្វើយ៉ាងណាដើម្បីធ្វើការរួមគ្នាឱ្យបានប្រសើរជាងនេះ ជាពិសេសក្នុងបរិបទកូវីដ១៩នេះ។



*លោកអភិបាលអូលីវីយ៉េ ថ្លែងក្នុងពិធីជួបជុំរិះគិតរបស់សម្ព័ន្ធអង្គការកាតូលិកដើម្បីមេត្តាករុណានិងការអភិវឌ្ឍ (CACD) កាលពីខែមករា នៅអង្គការការីតាសកម្ពុជា ក្នុងសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ។ រូបភាព៖ ព្រះសហគមន៍*

នាពិធីនោះដែរ លោកអភិបាលអូលីវីយ៉េ បានរំឮកអំពីអត្ថន័យនៃការប្រទានពរទាំង៥ដែលលោកបានប្រទានពរនៅក្នុងពិធីបុណ្យព្រះយេស៊ូសម្តែងឋានៈរបស់ព្រះអង្គ។ ពរទាំង៥នោះមាន សូមឱ្យយើងពោរពេញដោយព្រះពរពី ព្រះជាម្ចាស់។ សូមឱ្យឆ្នាំនេះយើងយកព្រះបន្ទូលជាប្រភពនៃជីវិត។ សូមឱ្យយើងយកចិត្តទុកដាក់ថែរក្សា និងចូលយ៉ាងជ្រៅនៅក្នុងអត្តសញ្ញាណរបស់យើងជាគ្រីស្តបរិស័ទខ្មែរ ក្នុងបរិបទថ្មី។ សូមឱ្យយើងយកចិត្តទុកដាក់លើជំនឿរបស់យើង និងសូមឱ្យយើងថែរក្សាសញ្ញាសម្គាល់នៅក្នុងជីវិតរបស់យើង។

លោកអភិបាល ភូមិភាគភ្នំពេញ បន្ថែមទៀតថា៖ «ជារៀងរាល់ឆ្នាំសម្តេចប៉ាបហ្វ្រង់ស៊ីស្សសរសេរសំបុត្រផ្ញើជូនពិភពលោក។ សម្តេចប៉ាបបានឃើញអ្វីដែលបានកើតឡើងក្នុងឆ្នាំ២០២០កន្លងទៅ ជាពិសេសលោកបានយល់ថា អ្វីដែលសំខាន់គឺការបង្កើតវប្បធម៌ថ្មី ដែលនាំឱ្យយើងយកចិត្តទុកដាក់ក្នុងការកសាងសន្តិភាព»។

នៅក្នុងកម្មវិធីនេះផងដែរ ក៏មានការបង្ហាញនូវរបាយការណ៍សកម្មភាពឆ្នាំចាស់កន្លងមក និងបានរិះគិតដោយចែកជាក្រុមតូចៗ ដើម្បីរួមគ្នាអំពីសារលិខិតរបស់សម្តេចប៉ាប ដោយក្នុងមាន៩ចំណុចយកមកពិចារណាគឺ៖ ១. ការបង្កើតវប្បធម៌ថ្មី ដែលនាំឱ្យយើងយកចិត្តទុកដាក់ក្នុងការកសាងសន្តិភាព។ ២. ការថែរក្សា និងការពារពិភពលោកដែលព្រះជាម្ចាស់បានបង្កើត។ ៣. មើលព្រះជាម្ចាស់ជាគំរូ ដោយព្រះជាម្ចាស់បង្កើតថ្ងៃទី៧ដើម្បីកោតសរសើរព្រះជាម្ចាស់ និងអ្វីដែលព្រះអង្គបានបង្កើត។ ៤. ព្រះបន្ទូល ៥. គ្រីស្តទូតបង្កើតឧបដ្ឋាក ដើម្បីយកចិត្តទុកដាក់លើអ្នកក្រីក្រ។ ៦. យកចិត្តទុកដាក់លើតម្លៃថ្លៃថ្នូររបស់មនុស្ស។ ៧. យកចិត្តទុកដាក់បង្កើតសាមគ្គីភាពដោយធ្វើដំណើរជាមួយគ្នាតរៀងទៅ។ ៨. បង្កើតកម្មវិធីសិក្សានៅក្នុងគ្រួសារ ដើម្បីបង្កើតវប្បធម៌ថ្មី និង៩. សន្តិភាពនឹងមិនប្រសើរបើយើងគ្មានវប្បធម៌នៃការយកចិត្តទុកដាក់៕

# អភិបាលភូមិភាគភ្នំពេញណែនាំគ្រីស្តបរិស័ទឱ្យយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលព្រះជាម្ចាស់

*អត្ថបទ៖ ដាលីស*

នាថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅព្រះវិហារសន្តយ៉ូសែបផ្សារតូចនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រារព្ធកម្មវិធី «អធិដ្ឋានសម្រាប់ការត្រាស់ហៅពេញមួយយប់លើកទី៩៨» ក្រោមការដឹកនាំពីលោក អូលីវីយ៉េ ឆ្មីតហាស្លេរ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងមានការចូលរួមពីគ្រីស្តបរិស័ទផងដែរ។

លោកអភិបាល អូលីវីយ៉េ បានថ្លែងក្នុងឱកាសនោះថា នេះជាវេលាមួយដ៏ល្អដើម្បីសូមព្រះជាម្ចាស់បើកចិត្តគំនិតយុវជនយុវនារីឱ្យដើរតាមព្រះជាម្ចាស់និងឱ្យមើលឃើញពីការត្រាស់ហៅរបស់ព្រះអង្គ។

នៅក្នុងពិធីបុណ្យអភិបូជាបើកកម្មវិធីអធិដ្ឋាននេះ លោកអភិបាលបានណែនាំគ្រីស្តបរិស័ទទាំងអស់នៅក្នុងធម្មទេសនាឱ្យយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកបានមានប្រសាសន៍ថា៖ «ប្រសិនបើយើងផ្ទាល់ខ្លួនមិនស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តើធ្វើដូចម្តេចនឹងអាចឆ្លើយតបបាន?»

លោកអភិបាលរូបនេះបានផ្តល់នូវអនុសាសន៍សំខាន់ចំនួន៤ដើម្បីដើរតាមព្រះជាម្ចាស់ គឺទី១ គ្រប់គ្នានៅជិតព្រះជាម្ចាស់ដែលមានឫទ្ធានុភាពសព្វប្រការ មិនវិនិច្ឆ័យធ្វើឱ្យធ្លាក់ទឹកចិត្ត និងអស់សង្ឃឹម។ តែផ្ទុយមកវិញ ដើម្បីណែនាំឱ្យចូលទៅក្នុងព្រះពន្លឺរបស់ព្រះអង្គ ដោយស្គាល់អ្វីល្អអ្វីអាក្រក់ និងប្រកាសដំណឹងល្អឱ្យគេកែប្រែចិត្តគំនិត។

លោកបន្តទៀតថា ចំណុចទី២គឺ វិញ្ញាណក្ខន្ធរបស់សន្តសន្តី ដែលដើរតាមព្រះជាម្ចាស់ គឺជាគំរូពិសេសនៅក្នុងការយកចិត្តទុកដាក់ស្រឡាញ់ព្រះជាម្ចាស់ និងជាវិញ្ញាណក្ខន្ធអ្នកសុច្ចរិត។ លោកអភិបាល អូលីវីយ៉េ លើកឡើងថា ៖ «ទី៣ នៅពេលយើងដើររកព្រះជាម្ចាស់ គឺយើងចូលមកស្ពាននៃសម្ព័ន្ធមេត្រីថ្មី ដោយមិននៅម្នាក់ឯង តែព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយយើងឆ្ពោះទៅរកព្រះបិតា»។ ឯអនុសាសន៍ទី៤គឺការយល់ពីរបៀបថ្មី ដោយចូលទៅក្នុងវប្បធម៌នៃការយកចិត្តទុដាក់ បង្កើតសមត្ថភាពនៅក្នុងភាតរភាពមានការសប្បាយ និងកសាងចិត្តគំនិតដើម្បីឱ្យមនុស្សយល់ថា [យើង]ជាមនុស្សពេញលក្ខណៈ។

លោក ប្រាក់ ប៊ុនហុង បានឱ្យដឹងថា ការអធិដ្ឋានពេញមួយយប់ពិតជាជួយច្រើនសម្រាប់ជីវិតនៃការត្រាស់ហៅ។

លោកបានប្រាប់ថា៖ «ការអធិដ្ឋានបានជួយឱ្យយើងរិះគិតអំពីអ្វីដែលព្រះជាម្ចាស់ត្រាស់ហៅយើង។ ជាពេលវេលាដែលយើងអធិដ្ឋានសម្រាប់ព្រះសហគមន៍របស់យើងដែរ ដោយសារភាគច្រើនព្រះសហគមន៍របស់យើងមានបញ្ហាផ្សេងៗយើងមិនដឹង ប៉ុន្តែយើងនឹកគិតដល់ព្រះសហគមន៍ នឹកគិតដល់គ្រីស្តបរិស័ទរបស់យើងឱ្យពួកគេខិតខំតស៊ូក្នុងជីវិតទាំងក្នុងគ្រួសារ និងឧបសគ្គផ្សេងៗដែលគាត់ជួប»។

លោកប្រាក់ ប៊ុនហុង បន្ថែមថា លោកក៏អធិដ្ឋានសម្រាប់យុវជន-យុវនារី ដែលកំពុងតែរិះគិត និងជួនកាលពួកគេមិនទាន់រកផ្លូវច្បាស់លាស់នៅក្នុងជីវិត ដូចជាជាគ្រូស្រករ ឬជាបព្វជិតបព្វជិតា ជាដើម ដើម្បីសូមព្រះវិញ្ញាណបំភ្លឺពួកគេឱ្យមានសេចក្តីក្លាហានក្នុងការរិះគិត។

លោកបានបញ្ជាក់ថា ៖ «ខ្ញុំក៏រិះគិតអំពីខ្លួនឯងចំពោះការឆ្លើយតបទៅព្រះជាម្ចាស់ក្នុងជីវិតនៃការត្រាស់ហៅឱ្យបានសមរម្យ ដើម្បីបំពេញកិច្ចការរបស់ព្រះអង្គ»។

ជារៀងរាល់ថ្ងៃព្រហស្បតិ៍នៃដើមខែនីមួយៗ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ តែងតែប្រារព្ធកម្មវិធីអធិដ្ឋានសម្រាប់ការត្រាស់ហៅនេះ ដោយផ្លាស់ប្តូរទីតាំងវិលជុំទៅតាមមណ្ឌលសកម្មភាពទាំង៩របស់ព្រះសហគមន៍ភូមិភាគភ្នំពេញ៕

## លោកអូលីវីយ៉េ៖ ក្នុងពេល៤០ថ្ងៃ ត្រូវយកចិត្តទុកដាក់ថែរក្សាជំនឿ សេចក្តីសង្ឃឹម សម្តែងធម៌មេត្តាករុណា និងតមអាហារ

*អត្ថបទដោយ៖ ដាលីស*

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញប្រារព្ធពិធីបុណ្យរោយផេះ ដែលជាប្រពៃណីព្រះសហគមន៍នាថ្ងៃដំបូងចូលក្នុងរដូវអប់រំពិសេស(រដូវ៤០ថ្ងៃឬរដូវត្រណម)។

ព្រះសហគមន៍ ប្រារព្ធបុណ្យរោយផេះដើម្បីរំឭកដល់គ្រីស្តបរិស័ទទាំងអស់ឱ្យរស់នៅដោយកែប្រែចិត្តគំនិត ជាពិសេសរំឭកអំពីកំណើតរបស់មនុស្សយើងដែលកើតមកពីធូលីដី និងស្លាប់ក៏ក្លាយ ទៅជាធូលីដីវិញ។

ពិធីបុណ្យនេះប្រារព្ធ នៅព្រះវិហារព្រះមាតានៃសន្តិភាព (អរិយក្សត្រ) ក្រោមអធិបតីភាពលោកអូលីវីយ៉េ ឆ្មីតហាស្លេរ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ និងមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករនាល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ។

តាមប្រសាសន៍ណែនាំរបស់លោកអភិបាលអូលីវីយ៉េ នៅក្នុងធម្មទេសនា លោកលើកឡើងថា រដូវ៤០ថ្ងៃដែលព្រះសហគមន៍អញ្ជើញយើងឱ្យធ្វើដំណើររួមជាមួយព្រះយេស៊ូ ដើម្បីទទួលមរណភាពនៅក្រុងយេរ៉ូសាឡឹម ក៏ប៉ុន្តែមរណភាពមិនបានបញ្ឈប់ដំណើររបស់យើងទេ ព្រោះបីថ្ងៃក្រោយមកព្រះយេស៊ូនឹងមានព្រះជន្មរស់ឡើងវិញ។

លោកបានបន្តថា ៖ «ដូច្នេះយើងធ្វើដំណើររួមជាមួយព្រះយេស៊ូដែលរងទុក្ខលំបាក សោយព្រះទិវង្គត់ រហូតដល់ព្រះអង្គមានព្រះជន្មរស់ឡើងវិញដោយរុងរឿងទៅគង់ខាងស្តាំព្រះបិតា»។

ជាមួយគ្នានេះដែរ លោកអូលីវីយ៉េ ក៏បានពញ្ញាក់ស្មារតីគ្រីស្តបរិស័ទភូមិភាគភ្នំពេញទាំងអស់នៅក្នុងឆ្នាំ២០២១នេះ ឱ្យរិះគិតឡើងវិញនូវបញ្ហាដែលយើងបានជួបកាលពីឆ្នាំ២០២០កន្លងទៅ ជាពិសេសជំងឺកូវីដ១៩នេះ តើយើងមានចំណុចខ្សោយនិងចំណុចខ្លាំងអ្វីខ្លះនៅក្នុងគ្រួសារ សង្គម និងព្រះសហគមន៍? តើ៤០ថ្ងៃខាងមុខនេះយើងនឹងធ្វើដូចម្តេចដើម្បីធ្វើជាមនុស្សថ្មី?

លោកអភិបាលភូមិភាគភ្នំពេញអូលីវីយ៉េ ក៏បានផ្តល់នូវអនុសាសន៍ចំនួន៥ចំណុចសម្រាប់ជួយដល់គ្រីស្តបរិស័ទដើម្បីធ្វើដំណើររួមជាមួយព្រះយេស៊ូក្នុង៤០ថ្ងៃខាងមុខនេះគឺ។ លោកមានប្រសាសន៍ថា៖ «សូមឱ្យយើងការពារថែរក្សាជំនឿរបស់យើងដោយផ្តល់សក្ខីភាពពិតប្រាកដ។ យកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលនិងអធិដ្ឋានថែមទៀត។ ថែរក្សាសេចក្តីសង្ឃឹមរបស់យើងដែលជាសញ្ញាសម្គាល់អំពីគ្រីស្តបរិស័ទ ទោះបីជាយើងមានទុក្ខលំបាកយ៉ាងណាក៏ដោយព្រោះយើងមានព្រះគ្រីស្ត មានព្រះបន្ទូល និងព្រះសហគមន៍ជាទីពឹងនៅក្នុងជីវិត»។

លោកអភិបាលរូបនេះបន្ថែមថា៖ «សូមធ្វើជាគ្រីស្តបរិស័ទមួយរូបដែលបង្ហាញពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ហើយនេះជាពេលវេលាដើម្បីជួយដល់អ្នកខ្វះខាត និងខ្វះសេចក្តីសង្ឃឹម។ នៅក្នុងរដូវ៤០ថ្ងៃនេះ ព្រះសហគមន៍អញ្ជើញយើងឱ្យតមអាហារ ដោយពិចារណា យកចិត្តទុកដាក់ចំពោះកម្លាំងកាយ និងកម្លាំងចិត្តរបស់យើងផ្ទាល់ខ្លួន និងយកចិត្តទុកដាក់ចំពោះបងប្អូនឯទៀតៗផងដែរ»។

លោកបន្ថែមថា អត្ថន័យនៃការតមអាហារមិនមែនឱ្យយើងឈប់ញ៉ាំទេ ប៉ុន្តែជារបៀបនៃការរស់នៅ និងទំនាក់ទំនងរបស់យើងនៅក្នុងជីវិតពិតប្រាកដ៕

# លោកអភិបាល ទេព ច័ន្ទពិសិដ្ឋ ៖ «យើងមានព្រះវិហារស្អាត សូមឱ្យបងប្អូនរៀបចំចិត្តគំនិតឱ្យបានស្អាតដូចគ្នាដែរ»



*ព្រះវិហារព្រះនាងម៉ារីមាតានៃសន្តិភាពប្រាបវាល នៃភូមិភាគបាត់ដំបង ដែលទើបតែបានប្រារព្ធអភិបូជាឆ្លងកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១។* ***រូបភាព៖ ភូមិភាគបាត់ដំបង***

*អត្ថបទ៖ សេង ស្រីមួយ*

នៅព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ព្រះវិហារព្រះនាងម៉ារីមាតានៃសន្តិភាពប្រាបវាល នៃភូមិភាគបាត់ដំបង ដែលទទួលខុសត្រូវដោយលោកបូជាចារ្យបុងបុង បានប្រារព្ធអភិបូជាឆ្លងព្រះវិហារថ្មី ដែលស្ថិតនៅភូមិប្រាបវាល ឃុំអន្លង់វិល ខេត្តបាត់ដំបង។

ពិធីនេះមានការអញ្ជើញចូលរួមក្រោមអធិបតីភាពលោកអភិបាលទេព ច័ន្ទពិសិដ្ឋ លោកបូជាចារ្យ បងប្រុសបងស្រី និងបងប្អូនគ្រីស្តបរិស័ទផងដែរ។

នៅក្នុងធម្មទេសនាលោកអភិបាលបានលើកឡើងថា ព្រះវិហារនេះជានិមិត្តរូប និងជាសញ្ញាសំគាល់ដែលបញ្ជាក់ថាមានគ្រីស្តបរិស័ទនៅភូមិប្រាបវាលនេះ សូមឱ្យបងប្អូនចូលរួមអធិដ្ឋាននៅក្នុងព្រះវិហារថ្មី។

លោកអភិបាលបានមានប្រសាសន៍ថា៖ «យើងមានព្រះវិហារស្អាត សូមឱ្យបងប្អូនរៀបចំចិត្តគំនិតឱ្យបានស្អាតដូចគ្នាដែរ និងសូមអោយបន្តលើកទឹកចិត្តគ្នាទៅវិញទៅមក រួមគ្នាកសាងព្រះសហគមន៍ បន្តដំណើរជាមួយគ្នាទៅរកមាគ៌ារបស់ព្រះជាម្ចាស់ សូមធ្វើជាគ្រឹះដ៏រឹងមាំរបស់ព្រះសហគមន៍»។



*លោកអភិបាល ទេព ច័ន្ទពិសិដ្ឋ អភិបាលព្រះសហគមន៍ ភូមិភាគបាត់ដំបង។* ***រូបភាព៖ ភូមិភាគបាត់ដំបង***

ក្នុងឱកាសនោះលោកបូជាចារ្យបុងបុងបានមានប្រសាសន៍ផងដែរថា៖ «គ្រីស្តបរិស័ទនៅទីនេះបានកសាងព្រះវិហារតូចមួយ ដែលធ្វើអំពីឈើនៅឆ្នាំ២០០០ ហើយយើងមានគ្រីស្តបរិស័ទតិច ដែលចូលរួមជាមួយយើង ប៉ុន្តែឥឡូវនេះយើងបានសាងសង់ព្រះវិហារថ្មីដើម្បីលើកទឹកចិត្តបងប្អូនគ្រីស្តបរិស័ទរួមគ្នាអធិដ្ឋានអោយបានប្រសើរជាងមុន»។ លោកបានបន្ថែមទៀតថា លោកបានទទួលខុសត្រូវព្រះសហគមន៍ប្រាបវាលអស់រយៈពេល២ឆ្នាំ គឺចាប់ពីឆ្នាំ២០១៩ ដល់បច្ចុប្បន្ននេះ លោកពិតជាមានចិត្តសប្បាយរីករាយ និងសូមអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានអំណោយទានដល់ព្រះសហគមន៍។

គួរបញ្ជាក់ផងដែរថាព្រះវិហារនេះបានសាងសង់ថ្មីដោយទទួលបានជំនួយពីសប្បុរសជនក្រៅប្រទេស គោលបំណងនៃការសាងសង់ព្រះវិហារនេះគឺដោយសារព្រះវិហារចាស់ តូចចង្អៀត និងមានទឹកលេចនៅពេលមានភ្លៀងធ្លាក់ ជាពិសេសគឺលើកទឹកចិត្តដល់បងប្អូនគ្រីស្តបរិស័ទឱ្យមានព្រះវិហារស្អាតសម្រាប់អធិដ្ឋានឱ្យបានសមរម្យ៕

# ពិធីបុណ្យរោយផេះនៅព្រះសហគមន៍ភូមិភាគភ្នំពេញ


ព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច


ព្រះសហគមន៍កាតូលិក សន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី


ព្រះវិហារមាតានៃសន្តិភាព អរិយក្សត្រ


ព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយេ ចំប៉ា


ព្រះសហគមន៍ព្រះកុមារយេស៊ូ បឹងទំពុន


ព្រះសហគមន៍បឹងឈូក


ព្រះវិហារសន្តម៉ាទីន ព្រែងត្រយឹង

# ព្រះសហគមន៍ភូមិភាគបាត់ដំបង


ព្រះវិហារសន្តហ្វ្រង់ស្វ័រសាវីយេ ស្វាយស៊ីសុផុន




ព្រះសហគមន៍កាតូលិកបាត់ដំបង


ព្រះសហគមន៍កាតូលិក ចំណោម



# ព្រះសហគមន៍ភូមិភាគកំពង់ចាម








ព្រះវិហារកំពង់ចាមក្រុង




ព្រះសហគមន៍កាតូលិកប៊ូស្រា


ព្រះសហគមន៍កាតូលិកបាវិត


ព្រះសហគមន៍មណ្ឌលគិរី